# គំរោងផែនការមេរៀនសំរាប់គ្រូ

សូមពិនិត្យទំព័រទី១ និងទី២ នៃ " របៀបប្រើសៀវភៅសំរាប់គ្រូ" សំរាប់ជាពត៌មានបន្ថែមអំពីប្រើ គំរោងផែន ការទាំងនេះ ។

# គំនិតទូទៅខ្លីៗរបស់មុខវិជ្ជា

**១.** មួយថ្ងៃ ឬ ពីរថ្ងៃមុនពេលបើកថ្នាក់ដំបូង អ្នកអាចណែនាំមេរៀននេះទៅដល់សិស្សទាំងអស់ និង ផ្ដល់ជូននូវកិច្ចការត្រូវធ្វើដំបូងរបស់ពួកគេ ។ ប្រសិនបើអាចធ្វើបាន សូមផ្ដល់សៀវភៅណែនាំការសិក្សាមួយថ្ងៃ ឬពីរថ្ងៃមុននឹងអ្នកចាប់ផ្ដើមបង្រៀនមុខវិជ្ជានេះ ។

**២.** នៅទំព័របន្ទាប់ពីនេះ (ទំព័រ ២) មានបញ្ជីកិច្ចការត្រូវធ្វើមួយសន្លឹក រួមជាមួយនឹងកាលបរិច្ឆេទ នៅពេលណាកិច្ចការត្រូវធ្វើត្រូវបានបំពេញរួច ។ ចូរអោយពួកគេបំពេញកាលបរិច្ឆេទអោយបានត្រឹមត្រូវដោយប្រើក្រដាស សនៅទំព័រនៃបញ្ជីកិច្ចការត្រូវធ្វើនៅខាងក្រោយនៃសៀវភៅណែនាំការសិក្សា ។

**៣.** ជំរាបអោយសិស្សដឹងថា ពួកគេត្រូវបញ្ចប់ គំរោង ទី ១ នៅពេលដែលពួកគេវិលមកចូលរៀនថ្នាក់ដំបូង ។ អ្នកអាចពន្យល់ដោយសង្ខេបនៃគំរោង ទី ២ ដល់សិស្ស ។ គំរោងនេះនឹងមិនផុតកំណត់យករហូតដល់ថ្នាក់ទី ២ ចាប់ផ្ដើម ។ សូមប្រាប់ពួកគេកុំចាប់ផ្ដើមគំរោង ទី ២ រហូតដល់មេរៀន ទី ១ ត្រូវបានបញ្ចប់ ។

**៤.** សៀវភៅណែនាំរបស់សិស្សអាចត្រូវផ្ដល់ដល់សិស្សពេលនេះតែម្ដង ។ អ្នកអាចអោយពួកគេអានទំព័រ ដែលអ្នកនឹងនាំពួកគេអោយទៅរកការសិក្សាសំរាប់មេរៀននេះ ។ ប៉ុន្ដែប្រសិនបើអ្នកធ្វើដូចនេះ សូមប្រាប់សិស្សអោយបញ្ចប់គំរោង ទី ១ មុននឹងពួកគេអានសៀវភៅណែនាំរបស់សិស្ស ។ ចំលើយចំពោះសំនួរខ្លះៗនៅលើគំរោង ទី ១ មាននៅក្នុងពីរបីទំព័រដំបូងនៃសៀវភៅណែនាំរបស់សិស្ស ។

> *អាកប្បកិរិយារបស់អ្នកត្រូវតែដូចខ្ញុំ បុត្រមនុស្សមកក្នុងពិភព លោកនេះមិនមែនដើម្បីអោយគេបំរើលោកទេ គឺលោកមកបំរើគេវិញ ព្រមទាំងបូជាជីវិត ដើម្បីលោះមនុស្សសទាំងអស់ផង ។*
>
> ព្រះយេស៊ូគ្រីស្ដ
> ម៉ាថាយ២០:២៨

# បញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់

**ចំណងជើងមេរៀន : អាកប្បកិរិយា**

| សំនួរខ្លីៗ | ខ ចងចាំ | កាលបរិច្ឆេទ |
|---|---|---|
| ១ | សុភាសិត ១០:១៧ | ថ្ងៃ ទី ២ |
| ២ | កាឡាទី ៦ :១ | ថ្ងៃ ទី ៣ |
| ៣ | ការមានអាកប្បកិរិយាខាងព្រះគម្ពីរនៅពេលដែលគេកែតម្រង់ | ថ្ងៃ ទី ៤ ឬក៏ ទី ៥ |

| គំរោង | ថ្ងៃខែផុតកំណត់ |
|---|---|
| ១ | ថ្ងៃ ទី ១ |
| ២ | ថ្ងៃ ទី ២ ឬក៏ ទី ៣ |
| ៣ | ថ្ងៃ ទី ២ |
| ៤ | ថ្ងៃ ទី ៣ ឬក៏ ថ្ងៃ ទី ៤ |
| ៥ | ថ្ងៃ ទី ៤ ឬក៏ ថ្ងៃ ទី ៥ |
| ៦ | ថ្ងៃ ទី ៣ |
| ៧ | ថ្ងៃ ទី ៣ |
| ៨ | ថ្ងៃ ទី ៤ |
| ៩ | ថ្ងៃ ទី ៥ ឬក៏ អាចជ្រើសរើសបាន |
| ១០ | ថ្ងៃ ទី ៥ ឬក៏ អាចជ្រើសរើសបាន |

**ការប្រលង :** កាលបរិច្ឆេទ ថ្ងៃ ទី ៥

# មេរៀន ទី ១
# តើអាកប្បកិរិយាគឺជាអ្វី?

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវតែបង្កើតអាកប្បកិរិយាថ្មីដើម្បីប្រើនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្ញុំ ។

## ២. ខ គម្ពីរសំខាន់ : អេភេសូ ៤:២៣

ត្រូវប្រែគំនិតប្រាជ្ញា និង វិញ្ញាណអោយបានថ្មីឡើង ។

## ៣. យោងតាមឯកសាររបស់សិស្ស

ជំពូក ទី ១ និង ទី ២ នៅទំព័រ ទី ៤-១២ ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោង ទី ១ " តើអាកប្បកិរិយាជាអ្វី? " នៅក្នុងសៀវភៅណែនាំការសិក្សាក៏ស៊ីគ្នាជាមួយនឹងមេរៀននេះផងដែរ ។

## ៤. ជំរើស ពីរថ្នាក់រៀន

ប្រសិនបើកាលវិភាគរបស់អ្នកអនុញ្ញាតអោយ អ្នកអាចយកពីរ ពេលក្នុងថ្នាក់រៀនដើម្បីបង្រៀនមេរៀនដំបូងនេះ ។ បញ្ហាសំខាន់ពីរដែលត្រូវបង្រៀននៅក្នុងមេរៀននេះអាចត្រូវបានបង្រៀនដាច់ចេញពីគ្នា :

១) តើអាកប្បកិរិយាគឺជាអ្វី?

២) តើមនុស្សបង្កើតអាកប្បកិរិយាថ្មីដោយរបៀបណា?

## ៥. ការចាប់ផ្តើមមេរៀន : ការបញ្ចាំងស្លាយ (៥-១០នាទី)

ចាប់ផ្តើមជាមួយថ្នាក់រៀនដោយបញ្ចាំងស្លាយដែលបង្ហាញ អាកប្បកិរិយាផ្សេងៗគ្នា ដែលយើងអាចមានចំពោះបញ្ហាផ្សេងៗគ្នា ។ សូមមើលកំណត់ចំណាំរបស់គ្រូ ដោយភ្ជាប់នឹងគំរោងមេរៀននេះ (ទំព័រ ទី ៩-១០)សំរាប់ការពន្យល់នូវសកម្មភាពនេះ ។

## ៦. តើអាកប្បកិរិយាគឺជាអ្វី? (៥-១០ នាទី)

សូមពិភាក្សាជាមួយសិស្សនូវនិយមន័យផ្សេងៗគ្នាខ្លះសំរាប់ពាក្យ " អាកប្បកិរិយា " ។ សូមអោយសិស្សអានចំលើយរបស់ពួកគេចំពោះសំនួរទី ១ នៅក្នុងគំរោង ទី ១ ។ " តើអាកប្បកិរិយាគឺជាអ្វី? " សរសេរចំលើយរបស់

ពួកគេនៅលើក្ដារខៀន ឬក៏ នៅលើម៉ាស៊ីនបញ្ចាំងស្លាយ ។ នៅចំនុចនេះក្នុងការពិភាក្សា សូមទទួលយកចំលើយរបស់ពួកគេ ទោះបីជាមិនត្រឹមត្រូវ ឬក៏ មិនត្រឹមត្រូវយ៉ាងណាក៏ដោយ ។

បន្ទាប់ពីពួកគេបានផ្ដល់គ្រប់ទាំងគំនិតទាំងអស់របស់ពួកគេ បន្ទាប់មកពន្យល់នូវនិយមន័យដែលយើងនឹងប្រើសំរាប់ពាក្យនេះនៅក្នុងការពិភាក្សាក្នុងថ្នាក់ ក្នុងមុខវិជ្ជានេះ ។ អោយពួកគេយោងទៅបញ្ជីនៃនិយមន័យនៅទំព័រ ទី ៤នៃសៀវភៅណែនាំរបស់សិស្ស ។

## ៧. ភាពខុសគ្នារវាងអាកប្បកិរិយា និងអារម្មណ៍ (៣-៥នាទី)

សូមធ្វើអោយប្រាកដថា សិស្សរបស់អ្នកយល់នូវភាពខុសគ្នារវាង អាកប្បកិរិយា និង អារម្មណ៍ ។ សូមអោយសិស្សរបស់អ្នកអានចំលើយរបស់ពួកគេចំពោះសំនួរ ទី ២ ក្នុងគំរោង ទី ១ ។ សំនួរនោះសួរពួកគេ អោយពន្យល់ពីភាពខុសគ្នារវាងអកប្បកិរិយា និង អារម្មណ៍ ។ បញ្ហានេះក៏ត្រូវបានបង្រៀនផងដែរនៅទំព័រ ទី ៥ ខាងដើម ក្នុងសៀវភៅណែនាំរបស់សិស្ស

## ៨. អាកប្បកិរិយា និង អាកប្បកិរិយាអាក្រក់ (៣-៥នាទី)

សិស្សអាចប្រើពាក្យ " អាកប្បកិរិយា" ដូចនេះ " គាត់មានអាកប្បកិរិយា " អ្វីដែលពួកគេចង់មានន័យគឺ " គាត់មានអាកប្បកិរិយាអាក្រក់ " ។ សូមធ្វើអោយប្រាកដថា នៅក្នុងមុខវិជ្ជានេះ យើងមិនកំណត់និយមន័យពាក្យថា អាកប្បកិរិយា តាមបែបនេះទេ ។ មានអាកប្បកិរិយាខ្លះល្អ និង មានអាកប្បកិរិយាខ្លះមិនល្អ ។ បង្ហាញដល់សិស្សរបស់អ្នកមើលពីការពន្យល់បង្ហាញនៅទំព័រ ទី ៥ ក្នុងសៀវភៅណែនាំរបស់សិស្ស ។

## ៩. តើគម្ពីរភីលីព ២:១-១១ចែងអំពីអាកប្បកិរិយាយ៉ាងដូចម្ដេច? (៤-៦ នាទី)

សូមអោយសិស្សអានចំលើយរបស់ពួកគេ ចំពោះសំនួរ ទី ៣ ក្នុងគំរោង ទី ១ ។( តើគម្ពីរភីលីព ២:១-១១ ប្រាប់អ្នកអំពីអាកប្បកិរិយាយ៉ាងដូចម្ដេច?) សង្កត់ត្រង់ចំនុចនេះថា យើងត្រូវមានអាកប្បកិរិយាដូចព្រះគ្រីស្ទមាន សូមមើល ខ ទី ៥ ។

## ១០. រ៉ូម ១២:២ ចំពោះអាកប្បកិរិយា (៤-៦នាទី)

សូមឱ្យសិស្សស្វែងរកមើល ហើយអានគម្ពីរ រ៉ូម ១២:២ ពីការបកប្រែផ្សេងៗគ្នាជាច្រើនរបស់ព្រះគម្ពីរ ។ ពិភាក្សា ដោយសង្ខេបអ្វីដែលខគម្ពីរនេះនិយាយអំពីអាកប្បកិរិយារបស់គ្រីស្ទបរិស័ទថ្មី ។

## ១១. សកម្មភាពក្រុមតូច " ការពាក់ និង ការដោះបោះចោល " (១៥-២៥នាទី)

សំរាប់សកម្មភាពបន្ទាប់នេះ សូមបែងចែកក្រុមក្នុងថ្នាក់ដែលមានគ្នា ៤ ឬ ៥ នាក់ក្នុងមួយក្រុម ។ (ប្រសិនបើក្នុងថ្នាក់មិនសូវមានសិស្ស សូមចែកយ៉ាងហោចណាស់អោយបានពីរក្រុម ។)

**ក.** ណែនាំអោយស្គាល់សកម្មភាពនេះដោយពន្យល់ថា ព្រះជាម្ចាស់ប្រាប់យើងក្នុងព្រះគម្ពីរឱ្យបោះបង់ចោលនូវអាកប្បកិរិយា និង ឥរិយាបថខ្លះ ។ ព្រះជាម្ចាស់ក៏មានព្រះបន្ទូលមកយើងអោយពាក់នូវអាកប្បកិរិយា និង ឥរិយាបថដទៃទៀត ។

**ខ.** ចាត់អោយក្រុមមួយ(ឬច្រើន) អាន កូឡូស ៣:១៥ ។ ហើយក្រុមដទៃអាន អេភេសូ ៤:១៧-៣២ ។

**គ.** សូមអោយក្រុមនីមួយៗធ្វើបញ្ជីពីរ ។
បញ្ជី លេខ ១ : តើអ្វីដែលយើងត្រូវយកចេញ ឬក៏ បោះបង់ចោល ។
បញ្ជី លេខ ២ : អ្វីដែលយើងត្រូវពាក់ ឬក៏ បង្កើតនៅក្នុងជីវិតរបស់យើង ។

សូមផ្តល់អោយពួកគេនូវក្រដាសធំៗ ២សន្លឹក (ក្រដាសក្រាស) និង ប៊ិចហ្វឺត ។ សូមអោយគេសរសេរបញ្ជីរបស់ពួកគេនៅលើក្រដាស ។(ផ្តល់ពេលអោយគេ ពី ៨-១២ នាទីដើម្បីបំពេញគំរោងនេះ) ។

**ឃ.** បន្ទាប់ពីពួកគេបានសរសេរចប់បញ្ជីរបស់ពួកគេហើយ យកបញ្ជីនោះមកខាងមុខថ្នាក់ ។
សូមអោយនរណាម្នាក់ ពីក្រុមនីមួយៗបង្ហាញការរកឃើញរបស់ពួកគេដល់ថ្នាក់ ។(៥-១០ នាទី)

## ១២. តើអាកប្បកិរិយាថ្មីអ្វីដែលអ្នកចង់បង្កើត? (៥-១០នាទី)

បើសិនជាអ្នកមានពេល អ្នកអាចពិភាក្សាសំនួរ ទី ៤ និង ទី ៥ ក្នុងគំរោង ទី ១ ។ ប៉ុន្តែប្រសិនបើអ្នកមិនមានពេលគ្រប់គ្រាន់ សូមរំលងសំនួរទាំងនេះ និងឆ្លោះទៅសំនួរ ទី ៦ ក្នុងគំរោង ទី ១ ។

៤. តើអ្នកទទួលអាកប្បកិរិយាដោយរបៀបណា ?
តើអ្នកបង្កើតអាកប្បកិរិយាដោយរបៀបណា?
៥. តើអ្នកប្រើអាកប្បកិរិយានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកដោយរបៀបណា?
៦. តើកន្លែងណានៅក្នុងជីវិតរបស់អ្នកដែលអ្នកចង់បង្កើតអាកប្បកិរិយាថ្មី?

អោយសិស្សធ្វើការសំគាល់ថា អាកប្បកិរិយាមួយណាដែលសំខាន់ជាងគេបំផុតសំរាប់គ្រីស្ទបរិស័ទថ្មីត្រូវផ្លាស់ប្តូរ ។ អោយពួកគេប្រើបញ្ជីពី អេភេសូ ៤:១៧-៣២ និង កូឡូស ៣:៥-១៥ ។ ពួកគេអាចប្រើចំលើយដែលពួកគេបានឆ្លើយក្នុងគំរោង ទី ១ សំនួរ ទី ៦ ផងដែរ ។ អ្នកអាចអោយសិស្សខ្លះពន្យល់ដោយសង្ខេបពីមូលហេតុ អាកប្បកិរិយាពិសេសទាំងនេះ ( អាកប្បកិរិយាដែលពួកគេបានលើកឡើង) សំខាន់បំផុតចំពោះគ្រីស្ទបរិស័ទថ្មី ។

## ១៣. អាកប្បកិរិយាសំខាន់ពីរនៅលើការកែតម្រង់

បន្ទាប់ពីសិស្សបានផ្តល់គំនិតរបស់ពួកគេ អំពីអាកប្បកិរិយាដែលសំខាន់បំផុតសំរាប់គ្រីស្ទបរិស័ទថ្មីដើម្បីបង្កើតឡើង នោះហើយ សូមបន្ថែមអាកប្បកិរិយាពីរ ខាងក្រោម ប្រសិនបើមិនមាននៅក្នុងបញ្ជីនោះ ។

- អាកប្បកិរិយារបស់ខ្ញុំ ពេលគេកំពុងតែកែតម្រង់ ( ឬតិទ្យេន ខ្ញុំ)
- អាកប្បកិរិយារបស់ខ្ញុំ ពេលខ្ញុំកំពុងតែកែតម្រង់អ្នកដទៃ ដែលខ្ញុំគិតថា បានធ្វើខុសនោះ ។

សូមពន្យល់ពួកគេថា យើងនឹងចំណាយពេលមួយមេរៀនទៀត នៅលើអាកប្បកិរិយាទាំងពីរនេះ ។ អ្នកអាចអោយសិស្សបង្ហាញទៅលើបញ្ជីនៃអាកប្បកិរិយាដែលត្រូវបានផ្តល់អោយនៅទំព័រ ទី ៧ ក្នុងសៀវភៅណែនាំរបស់សិស្ស ក្រោម ចំនុច **ក.** " តើកន្លែងណានៅក្នុងជីវិតរបស់ខ្ញុំដែលត្រូវការបង្កើតអាកប្បកិរិយាថ្មី? "

## ១៤. តើខ្ញុំគួរតែចាប់ផ្តើមបង្កើតអាកប្បកិរិយាថ្មីនៅកន្លែងណា? (៥ នាទី)

កំឡុងពេលរៀនបន្ទាប់ទៅនេះ យើងនឹងផ្តោតការយកចិត្តទុកដាក់របស់យើង ពីរបៀបដែលយើងអាចផ្លាស់ប្តូរអាកប្បកិរិយារបស់យើង ។ នៅក្នុងផ្លូវដ៏សង្ខេបមួយ សូមពិភាក្សាមេរៀននៅទំព័រ ទី ៨-៩ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ក្នុងជំពូក ទី ២ ចំនុច ខ " តើខ្ញុំគួរតែចាប់ផ្តើមបង្កើតអាកប្បកិរិយាថ្មីនៅកន្លែងណា? " អ្នកអាចប្រើឧទាហរណ៍ដែលត្រូវបានផ្តល់អោយនៅក្នុងសៀវភៅណែនាំរបស់សិស្សដើម្បីពន្យល់បង្ហាញនូវ ៥ ចំនុចដែលត្រូវបានបង្ហាញនៅក្នុងផ្នែកនេះរបស់មេរៀន ( អាកប្បកិរិយារបស់នរណាចំពោះការងារ) ។

## ១៥. តើវិធីសាស្ត្រអ្វីនឹងជួយខ្ញុំអោយបង្កើតអាកប្បកិរិយាថ្មី? (១៥-២៥នាទី)

សូមចំណាយពេលដ៏មានតំលៃក្នុងការពិភាក្សាចំនុច **គ.** " តើវិធីសាស្ត្រអ្វីនឹងជួយខ្ញុំអោយបង្កើតអាកប្បកិរិយាថ្មី? " សូមមើលទំព័រ ទី ៩-១២ ក្នុងសៀវភៅណែនាំរបស់សិស្ស ។ សូមព្យាយាមផ្តល់នូវការពន្យល់បង្ហាញជាច្រើននៃចំនុចនីមួយៗរបស់វិធីសាស្ត្រទាំង ៤ដែលត្រូវបានផ្តល់ជូននៅក្នុងសេចក្តីណែនាំរបស់សិស្ស ។

## ១៦. សេចក្តីសន្និដ្ឋាន/ការអនុវត្តន៍ផ្ទាល់ខ្លួន (១០-២០នាទី)

សូមអោយសិស្សបើកមើលនៅ គំរោង ទី ២ " *ការផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នក* " នៅក្នុងសៀវភៅការណែនាំការសិក្សា ។

ក. សូមអោយសិស្សឆ្លើយសំនួរ ទី ១-៥ ភ្លាមៗ ។

ខ. សូមចែកជាក្រុម ( ១ ក្រុមមាន ៣ នាក់ ) ហើយចែកចាយចំលើយរបស់គេ ក្នុងសំនួរទី ៤ នៅក្នុង គំរោង ទី ២ " តើខគម្ពីរណាមួយដែលនិយាយអំពីអាកប្បកិរិយាដែលមានសារៈប្រយោជន៍បំផុតសំរាប់អ្នក? " សូមអោយពួកគេពន្យល់ដល់មនុស្សដទៃទៀតពីមូលហេតុខគម្ពីរនេះមានសារៈប្រយោជន៍ចំពោះពួកគេ ។

គ. ប្រសិនបើពួកគេអ្នកចង់ ពួកគេអាចចែកចាយចំលើយរបស់ពួកគេនៅសំនួរ ទី ៥ " តើអាកប្បកិរិយាមួយណានៅ ក្នុងជីវិតរបស់អ្នក ដែលអ្នកចង់ផ្លាស់ប្តូរ ? "

ឃ. បន្ទាប់មក សូមអោយគេអធិស្ឋានសំរាប់ដៃគូរបស់ពួកគេ សុំជំនួយពីព្រះដើម្បីកែប្រែអាកប្បកិរិយារបស់ពួកគេ ។

ង. ប្រសិនបើអ្នកមានពេលគ្រប់គ្រាន់ សូមអោយសិស្សឆ្លើយសំនួរទី ៦ នៅលើគំរោងទី ២ មុនពេលចាកចេញពីថ្នាក់រៀន ។ " សូមបង្ហាញកិច្ចការមួយដែលអ្នកអាចធ្វើនៅក្នុង ២៤ ម៉ោងបន្ទាប់ទៀតដើម្បីជួយផ្លាស់ប្តូរនូវអាកប្បកិរិយានេះ ? "

## ១៧. កិច្ចការត្រូវធ្វើ

ក. សូមអោយសៀវភៅណែនាំរបស់សិស្ស បើសិនអ្នកមិនទាន់បានអោយនៅឡើយនោះ ។

ខ. ដាក់ពិន្ទុលើគំរោង ទី ១ ។

គ. រំលឹកដល់សិស្សថា គំរោង ទី ៣ " បទពិសោធន៍ពីអតីតកាលរបស់ខ្ញុំ ក្នុងការគេកែតម្រង់ និង តិទៀនខ្ញុំ" ត្រូវតែធ្វើអោយហើយមុនពេលចាប់ផ្តើមរៀនមេរៀននៅលើ *អាកប្បកិរិយា ។*

## ១៨. ការវាយតំលៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក?

# សៀវភៅកត់ចំណាំរបស់គ្រូ

## ការបញ្ចាំងស្លាយនៅលើអាកប្បកិរិយា

សកម្មភាពនេះត្រូវបានប្រើដើម្បីណែនាំអោយស្គាល់នូវមេរៀន ទី ១ ដល់សិស្ស ។ (សូមមើលចំនុចទី ៥ នៅលើទំព័រ ទី ៣ ក្នុងគំរោងមេរៀន ទី ១) សិស្សរបស់អ្នកគួរតែបំពេញអោយរួចរាល់ នូវគំរោង ទី ១ នៅក្នុងសៀវភៅណែនាំការសិក្សារបស់ពួកគេ មុននឹងអ្នកចាប់ផ្តើមមេរៀនដំបូង ។ សំនួរ ទី ១ និង ទី ២សួរអោយពួកគេកំណត់និយមន័យពាក្យថា អាកប្បកិរិយា ។

ចំនុចសំខាន់នៃការបង្ហាញស្លាយនេះ គឺដើម្បីឱ្យមានការចាប់អារម្មណ៏ក្នុងការមើលអោយស៊ីជំរៅ លើអាកប្បកិរិយាខ្លះៗដែលជះឥទ្ធិពលដល់ឥរិយាបថប្រចាំថ្ងៃរបស់គេ ។

## ការរៀបចំ

សូមធ្វើក្រដាសធំៗ ដាច់ដោយឡែកពីគ្នានៃឃ្លានីមួយៗនិយាយអំពីអាកប្បកិរិយា ដែលត្រូវបានបង្ហាញខាងក្រោមនេះ ។ អ្នកអាចដាក់បន្ថែមនូវឃ្លាជាច្រើនទៀតដែលបកស្រាយអំពីអាកប្បកិរិយាសំខាន់ៗ ។ ព្យាយាមកែច្នៃអក្សរដោយផាត់ពណ៌លើផ្ទាំងស្លាយហើយឆ្លាក់ពណ៌លើពាក្យស្តីអំពីអាកប្បកិរិយា ។ សូមយកផ្ទាំងស្លាយនីមួយៗមកបញ្ចាំង ។ អ្នកត្រូវការមានកញ្ចក់ផ្ទៃស្លាយ ៣៥ មម ជាមួយកញ្ចក់បញ្ចាំងនៅជិត ដើម្បីបញ្ចាំង ។

អ្នកមិនចាំបាច់ប្រើស្លាយក៏បានដែរសំរាប់ការបង្ហាញនេះ ។ អ្នកអាចប្រើក្រដាសធំៗសរសេរឃ្លាអំពីអាកប្បកិរិយាក៏បាន ។

## ឃ្លាស្តីអំពីអាកប្បកិរិយា

១. វិន័យត្រូវបានបង្កើតឡើង ដើម្បីមានការប្រព្រឹត្តខុស
២. ក្នុងនាមជាអ្នកដឹកនាំដែលមានអំណាចកាន់តែខ្លាំង ពួកគេពុករលួយកាន់តែខ្លាំង
៣. ផ្លែប៉ោមដែលគេបានលួចបាត់ទៅមានរស់ជាតិផ្អែមបំផុត
៤. អ្វីៗទាំងអស់ដែលមានតំលៃពិតប្រាកដ គឺឈ្នះការប្រកួត
៥. លុយមិនអាចទិញសុភមង្គលពិតបានទេ
៦. សេចក្តីស្រលាញ់អាចដោះស្រាយរាល់បញ្ហាទាំងអស់នៅលើពិភពលោក
៧. នយោបាយគួរអោយធុញទ្រាន់ណាស់
៨. យើងមិនមានការប្រកាន់ពូជសាសន៍ទេ យើងស្អប់មនុស្សរាល់គ្នា
៩. មនុស្សដែលមានសក់ និង សំបុរទង់ដែងគួរអោយស្រលាញ់
១០. មនុស្សចិត្តទូលាយតែងតែក្លាយជាអ្នកមាន
១១. ហេតុអ្វីត្រូវធ្វើការប្រសិនបើអ្នកអាចទទួលសុខមាលភាពហើយនោះ
១២. គ្រប់រឿងទាំងអស់ដែលអ្នកអាចធ្វើទៅបាន ខ្ញុំអាចធ្វើបានល្អជាងនេះទៅទៀត

## ការបង្ហាញនៅក្នុងថ្នាក់

សូមណែនាំអោយស្គាល់ការបង្ហាញស្លាយ ជាមួយនឹងការបកស្រាយខ្លីៗ អំពីអាកប្បកិរិយាផ្សេងៗគ្នាជាច្រើនដែលមនុស្សមានសព្វថ្ងៃនេះ ។ សូមប្រាប់ពួកគេអោយគិតអំពីអាកប្បកិរិយាដែលនូវបង្កប់ពីក្រោយរបស់ឃ្លានីមួយៗនៅក្នុងការបង្ហាញនេះ ។

នៅពេលអ្នកបង្ហាញស្លាយនេះ សូមធ្វើដោយស្ងាត់ស្ងៀម ។ សូមកុំចំណាយពេលវេលាពិភាក្សាឃ្លានីមួយៗ ។ គោលបំណងរបស់យើងគឺគ្រាន់តែចង់ជំរុញចំណាប់អារម្មណ៍នៅក្នុងការសិក្សាអាកប្បកិរិយាប៉ុណ្ណោះ ។

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការបង្ហាញស្លាយចប់ទៅ សូមចូលខ្លួនទៅពិភាក្សាអំពីអ្វីទៅជាអាកប្បកិរិយា ។ នៅក្នុងថ្នាក់ទាំងមូល អ្នកអាចយោងទៅលើឃ្លាស្តីអំពីអាកប្បកិរិយាទាំងនេះដើម្បីពន្យល់បង្ហាញបញ្ហាខ្លះៗដែលកំពុងតែត្រូវបានពិភាក្សានេះ ។

# មេរៀន ទី ២
# គេកំពុងកែតម្រង់ និង តិទៀនខ្ញុំ

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវតែចងចាំ និង ប្រើអាកប្បកិរិយាខាងព្រះគម្ពីរ នៅពេលដែលគេកែតម្រង់ និង តិទៀនខ្ញុំ ។

## ២. ខ គម្ពីរសំខាន់ : សុភាសិត ១០:១៧

អ្នកណាប្រតិបត្តិតាមដំបូន្មាន អ្នកនោះដើរទៅកាន់ផ្លូវជីវិត រីឯអ្នកដែលមិនព្រមទទួលការស្តីប្រដៅរមែងវង្វេងផ្លូវ ។

## ៣. យោងតាមឯកសាររបស់សិស្ស

ជំពូក ទី ៣ នៅក្នុងសៀវភៅណែនាំរបស់សិស្ស (ទំព័រ ទី ១៣-២៦) ស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោងខាងក្រោមពីសៀវភៅការណែនាំការសិក្សាក៏ស៊ីគ្នាជាមួយនឹងមេរៀននេះផងដែរ ។

គំរោង ទី ៣ *បទពិសោធន៍ពីអតីតកាលរបស់ខ្ញុំ ក្នុងការគេកែតម្រង់ និង តិទៀនខ្ញុំ ។*

គំរោង ទី ៤ *ការមើលឡើងវិញនៅការកែតម្រង់ និង ការតិទៀន ។*

គំរោង ទី ៥ *ការប្រើអាកប្បកិរិយាថ្មីរបស់ខ្ញុំនៅពេល ដែលនរណាម្នាក់កែតម្រង់ខ្ញុំ*

## ៤. ការចាប់ផ្តើមមេរៀន : " សូមផ្តល់ពិន្ទុនៅលើការកែតម្រង់ " (៥ នាទី)

សូមប្រាប់រឿងពីជីវិតរបស់អ្នកដែលនរណាម្នាក់បានកែតម្រង់ និង តិទៀនអ្នក ។ សូមធ្វើឱ្យប្រាកដថា អ្នកប្រាប់ពីរបៀបដែលអ្នកបានឆ្លើយតបចំពោះការតិទៀន ឬក៏ ការកែតម្រង់ ។ បន្ទាប់មកសួរសិស្សអោយផ្តល់តំលៃនូវកត្តាខាងក្រោមរបស់រឿងនេះ ។

(១) ផ្តល់តំលៃ ថាតើអំពើបាប, កំហុស ឬក៏ បរាជ័យនោះធ្ងន់ធ្ងរប៉ុណ្ណាមនុស្សណាម្នាក់ដែលត្រូវបានគេតិទៀន និង កែតម្រង់ ។ សូមប្រើ លេខ ១ ដល់ លេខ ១០ ក្នុងការថ្លឹងថ្លែង លេខ ១ បញ្ហាមិនធ្ងន់ធ្ងរ និង លេខ ១០ ធ្ងន់ធ្ងរ ។

(២) ផ្តល់តំលៃថាតើការងារដែលមនុស្សបានធ្វើនៅក្នុងការកែតម្រង់ ឬក៏ តិទៀនគេបានល្អដល់កំរិតណា ។ សូមប្រើ លេខ ១ ដល់ លេខ ១០ ក្នុងការថ្លឹងថ្លែង លេខ ១ មានន័យថា ធ្វើមិនបានល្អ ក្នុងការកែតម្រង់ ឬក៏ តិទៀនគេ លេខ ១០ មានន័យថា ធ្វើបានល្អណាស់ក្នុងការកែតម្រង់អ្នកដទៃ (ជាមួយនឹង ចិត្តសប្បុរស និង ការយល់ដឹងខាងវិញ្ញាណ)

(៣) ផ្តល់តំលៃ ថាតើអ្នកគិតថាមនុស្សបានឆ្លើយតប នៅពេលមុន ឬក៏ ក្រោយគេកែតម្រង់ ឬក៏ តិទៀនគាត់បានល្អប៉ុណ្ណា ។ សូមផ្តល់ពិន្ទុ រវាង (១) ដល់ (១០) ប្រសិនបើអ្នកផ្តល់ លេខ (១) អ្នកគិតថា គាត់បានឆ្លើយតបមិនល្អទេចំពោះការកែតម្រង់ ឬក៏ តិទៀន ។ ប្រសិនបើអ្នកផ្តល់លេខ (១០) មានន័យថា គាត់បានធ្វើការឆ្លើយតបយ៉ាងល្អ ។

សកម្មភាពនេះគ្រាន់តែសំរាប់ការសើចសប្បាយប៉ុណ្ណោះ និង ត្រូវបានរៀបចំឡើងដើម្បីជំរុញការគិតរបស់ពួកគេអំពីបញ្ហាដែលយើងចង់បង្រៀននៅក្នុងថ្នាក់ថ្ងៃនេះ ។ សូមជៀសវាងការពិភាក្សាវែងពេកចំពោះចំនុចនេះ ។ អ្នកអាចយោងចំពោះការពន្យល់បង្ហាញទាំងនេះនៅក្នុងពេលវេលាថ្នាក់រៀនទាំងមូល ។

## ៥. ជំរើសថ្នាក់រៀនពីរ

មានពតិមានជាច្រើនដែលស៊ីជាមួយនឹងមេរៀននេះ ។ សក្តានុពលភាពសំរាប់ការពិភាក្សាដ៏ធំទូលាយមួយអាចលើកទឹកចិត្តអ្នកដើម្បីមានផែនការបង្រៀនកិច្ចការនេះនៅក្នុងថ្នាក់រៀនពីរវគ្គ វាប្រសើរជាងមួយវគ្គ ។

## ៦. លើកឡើងខ្លីៗនៅពេលចាប់ផ្តើមពីរបៀបថ្នាក់រៀនថ្ងៃនេះដែលទាក់ទងនៅនឹងមេរៀនទី ៣

សូមប្រាប់សិស្សអោយទុកសំនួររបស់ពួកគេ និង ការពន្យល់បកស្រាយស្តីអំពី *របៀបកែតម្រង់នរណាម្នាក់ផ្សេងទៀត* ទុករហូតដល់មេរៀន ទី ៣ ។ ថ្ងៃនេះយើងនឹងពិភាក្សាអ្វីដែលគួរតែជាអាកប្បកិរិយារបស់ខ្ញុំនៅពេលគេកំពុងតែកែតម្រង់ខ្ញុំ ។ សូមលើកឡើងផងដែរនូវអាកប្បកិរិយាដូចគ្នានេះអាច និង គួរតែត្រូវបានប្រើនៅក្នុងស្ថានភាពដែលគេកំពុងតែតិទៀនខ្ញុំ ។

## ៧. ចែកចាយឧទាហរណ៍ផ្ទាល់ខ្លួននៃការដែលត្រូវបានគេតិទៀន ឬក៏ កែតម្រង់ (៥-១០ នាទី)

អ្នកអាចឱ្យសិស្សមួយចំនួនពិពណ៌នា ដល់សិស្សនៅក្នុងថ្នាក់ដោយលើកឧទាហរណ៍ ដែលពួកគេបានសរសេរនៅក្នុង គំរោង ទី ៣ ស្តីអំពី " *បទពិសោធន៍ពីអតីតកាលរបស់ខ្ញុំ ក្នុងការគេកែតម្រង់ និង តិទៀនខ្ញុំ ។* " សូមព្យាយាមជៀសវាងការពិភាក្សាលំអិតណាមួយថាតើនរណាត្រូវ នរណាខុសនោះ ។ អោយពួកគេបង្ហាញនូវឧទាហរណ៍ និង ការបកស្រាយរបស់ពួកគេពីរបៀបវាស្របគ្នាទៅនឹងប្រធានបទថ្ងៃនេះសំរាប់ការពិភាក្សា ។

ប្រសិនបើសិស្សមិនចង់ចែកចាយនូវឧទាហរណ៍ របស់ពួកគេនោះទេ សូមអ្នកផ្តល់នូវការពន្យល់ខ្លះពីជីវិតរបស់អ្នកផ្ទាល់ ឬក៏ ពីសិស្សពីមុន ។ អ្នកអាចលើកឡើងដោយសង្ខេបខ្លះៗពីគំនិតដែលត្រូវបានផ្តល់នៅក្នុង គំរោង ទី ៣ ចំនុច ក " *ហេតុអ្វីបានជាមនុស្សធ្វើបាបខ្ញុំ?* " សូមមើលទំព័រ ទី ១៣នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។

## ៨. អំពើបាបរបស់ព្រះបាទដាវីឌជាមួយនឹង នាង បាតសេបា (៥-១៥ នាទី)

រឿងអំពើបាបរបស់ព្រះបាទដាវីឌ និង បាតសេបា ហើយនឹងអ៊ូរី នៅក្នុង ២ សាម៉ូអែល ១១:១២, ១២:២៥ គឺជាគំរូមួយយ៉ាងច្បាស់លាស់ខាងព្រះគម្ពីររបស់មនុស្សក្នុងការឆ្លើយតបយ៉ាងសមរម្យនៅពេលដែលត្រូវបានគេកែតម្រង់ ។ អ្នកអាចអោយសិស្សម្នាក់សង្ខេបរឿងដល់ថ្នាក់ទាំងមូល ។ សូមផ្តោតការយកចិត្តទុកដាក់យ៉ាងពិសេសទៅលើ ២ សាម៉ូអែល ១២:១-១៤ ដែលជាកន្លែងកត់ត្រាការសន្ទនារវាង ព្យាការី ណាថាន និង ព្រះប្រាទដាវីឌ ។ សូមពិភាក្សាការឆ្លើយតបរបស់ព្រះបាទដាវីឌ នៅពេលដែល ព្យការីណាថាន បានចង្អុលបង្ហាញអោយឃើញអំពើបាបរបស់គាត់ ។ អ្នកអាចអានផងដែរនូវព្រះគម្ពីរ ទំនុកដំកើង ជំពូក ៥១ ដែលត្រូវបានសរសេរឡើងបន្ទាប់ពីណាថានបានមកជួបព្រះបាទដាវីឌ ។

វាអាចមានប្រយោជន៍ច្រើនជាងដើម្បីពិភាក្សាដោយសង្ខេបអំពីរឿងនៅក្នុងព្រះគម្ពីរនេះ ។ បន្ទាប់មកឱ្យសិស្សអាន ២ សាម៉ូអែល ១១ និង ១២ និង អាន ទំនុកតម្កើង ៥១ មុនថ្នាក់មួយទៀតចាប់ផ្តើម ។ ទំនុកតម្កើង ជំពូក ៥ គឺជាការបង្ហាញមួយយ៉ាងល្អនៃអាកប្បកិរិយារបស់ព្រះបាទដាវីឌ បន្ទាប់ពីព្រះបាទដាវីឌត្រូវបានគេកែតម្រង់ ។ អ្នកអាចឱ្យពួកគេពិពណ៌នាពីផែនការ ណាថាន...បានប្រើក្នុងការកែតម្រង់ព្រះបាទដាវីឌ ។ កិច្ចការនេះក៏ត្រូវបានប្រើផងដែរនៅក្នុងមេរៀន ទី ៣ នៅពេលដែលយើងនឹងពិភាក្សាពីរបៀបកែតម្រង់អ្នកដទៃ ។

## ៩. ឧទាហរណ៍ខាងព្រះគម្ពីររបស់មនុស្សដែរបានឆ្លើយតបចំពោះការកែតម្រង់

ជាមួយនឹងអាកប្បកិរិយាខុសឆ្គង (៥-១០ នាទី)

អ្នកអាចលើកឡើងថា មានឧទាហរណ៍ជាច្រើននៅក្នុងព្រះគម្ពីរនៃមនុស្សដែលបានឆ្លើយតបចំពោះការកែតម្រង់ជាមួយនឹងអាកប្បកិរិយាខុសឆ្គង ។

(១) អាដាំ និង អេវ៉ា - ពួកគេមិនទទួលកំហុសចំពោះអំពើបាបរបស់ពួកគេផ្ទាល់ខ្លួននៅក្នុងសួនអេដែននោះទេ ។

(២) កាអ៊ីន - គាត់បដិសេធន៍ការកែតម្រង់របស់ព្រះជាម្ចាស់អំពីដង្វាយរបស់គាត់ចំពោះព្រះជាម្ចាស់ ។

(៣) ហេរ៉ូដ- គាត់មិនបានធ្វើតាមការកែតម្រង់របស់លោកយ៉ូហានបាទីសចំពោះអាពាហ៍ពិពាហ៍របស់គាត់ជាមួយនឹងហារូឌីទេ ។

(៤) អ្នកមានជាអ្នកគ្រប់គ្រង - គាត់មិនហ៊ានលះបង់ទ្រព្យសម្បត្តិគាត់ទេ ។

(៥) សាដូស៊ី និងផារិស៊ី - ពួកគេបដិសេធន៍ ការកែតម្រង់របស់ព្រះយេស៊ូ ។

## ១០. ការណែនាំអោយស្គាល់អាកប្បកិរិយាថ្មីក្នុងការប្រើនៅពេលកំពុងតែត្រូវបានគេកែតម្រង់ (៥-១០នាទី)

រំលឹកម្តងទៀតនូវនិយមន័យរបស់អាកប្បកិរិយា (ទំព័រ ទី ៤ ក្នុងសៀវភៅណែនាំរបស់សិស្ស) ។ សូមពន្យល់ថា អាកប្បកិរិយាគឺជាគំរូនៃការគិត ។ ក្រុមនៃគំនិតនេះនឹងនាំយើងកំណត់ពីរបៀបយើងឆ្លើយតបចំពោះស្ថានភាពដែលត្រូវបានផ្តល់ជូន ។

សូមបង្រៀនយ៉ាងលឿននូវគំនិតនិមួយៗ ដែលបង្កើតឡើងនៅអាកប្បកិរិយាថ្មី ដើម្បីប្រើនៅពេលដែលគេកំពុងតែត្រូវបានកែតម្រង់ ឬក៏ តិទៀន ។ សូមអោយសិស្សយោងទៅលើគំនិតទាំងនេះនៅលើ ទំព័រ ទី ១៤នៃសៀវភៅណែនាំរបស់សិស្ស ឬក៏ ក្នុងជួរមួយក្នុងតារាងនៅលើទំព័រ ទី ២៤ និង ២៥ ។

បន្ទាប់មកអោយសិស្សអាន និង ពិភាក្សាអត្ថបទខគម្ពីរដែលស៊ីគ្នាជាមួយនឹងគំនិតនិមួយៗ ។ អត្ថបទខគម្ពីរទាំងនេះត្រូវបានបង្ហាញនៅក្នុងជួរ ទី ៦ នៃតារាង នៅក្នុងទំព័រ ទី ២៤ និង ២៥ ក្នុងសៀវភៅណែនាំរបស់សិស្ស ។

នៅត្រង់ចំនុចនេះកុំបង្ហាញទាំងអស់នូវពតិមានដែលនៅសល់នៅលើតារាងដែលស៊ីគ្នាជាមួយនឹងអាកប្បកិរិយានេះ នៅលើទំព័រ ទី ២៤ និង ២៥នៃសៀវភៅណែនាំរបស់សិស្ស ។

## ១១. ពន្យល់បង្ហាញអាកប្បកិរិយាថ្មីនេះ (៥-១០ នាទី )

ផ្តល់ឧទាហរណ៍ ២ ឬក៏ ៣ ពីរបៀបមនុស្សបានប្រើអាកប្បកិរិយានេះ និង អ្វីដែលបានកើតឡើង ។ ប្រើឧទាហរណ៍ពីជីវិតផ្ទាល់របស់អ្នក ឬក៏ ពីសិស្សនៅក្នុងអតីតកាលដែលបានបញ្ចប់គំរោងទី ៥ " ការប្រើអាកប្បកិរិយាថ្មីរបស់ខ្ញុំនៅពេល ដែលនរណាម្នាក់កែតម្រង់ខ្ញុំ " ។

ព្យាយាមបង្ហាញពីរបៀបដែលត្រូវបានគេប្រើ ឬក៏ មិនត្រូវបានគេប្រើនូវជំហាននិមួយៗ និង លទ្ធផលនៃការប្រើអាកប្បកិរិយាថ្មីនេះ ។ អ្នកអាចយោងទៅលើឧទាហរណ៍នៅពេលដែល ណាថាន បានកែតម្រង់ព្រះបាទដាវីឌ និង ពីរបៀបដែលព្រះបាទដាវីឌបានឆ្លើយតបចំពោះការកែតម្រង់នោះ ។

## ១២. មើលឡើងវិញនូវ បទពិសោធន៍ពីអតីតកាលរបស់ខ្ញុំ ក្នុងការគេកែតម្រង់

សិស្សរបស់អ្នកភាគច្រើនគួរតែមានឧទាហរណ៍ច្បាស់លាស់ខ្លះៗនៅលើគំរោង ទី ៣ របស់ពួកគេនៃពេលវេលាដែលពួកគេត្រូវគេកែតម្រង់ ឬក៏ តិទៀន ។ ប្រហែលជាពួកគេភាគច្រើនយល់ព្រមថា ពួកគេមិនបានឆ្លើយតបជាមួយនឹងអាប្បកិរិយាខាងព្រះគម្ពីរនោះទេពេលដែលពួកគេនៅក្នុងស្ថានភាពនោះ ។

អ្នកអាចចាប់ផ្តើមផ្នែកនៃការពិភាក្សានេះដោយផ្តល់នូវឧទាហរណ៍ពីជីវិតផ្ទាល់របស់អ្នក ។ កិច្ចការនេះអាចបង្កើតអោយមានបរិយាកាសប្រកបទៅដោយការបើកចំហរ និង ធ្វើអោយមានការងាយស្រួលសំរាប់ពួកគេមើលឃើញនូវអ្វីដែលអ្នកកំពុងចង់បាននៅទីនេះ ។

## ១៣. ផលប្រយោជន៍នៃការប្រើអាកប្បកិរិយានេះ (៥-១០ នាទី )

អោយសិស្សបង្ហាញបញ្ជីដល់អ្នកនូវអ្វីដែលពួកគេយល់ដឹងថាជាផលប្រយោជន៍នៃការប្រើអាកប្បកិរិយាថ្មីនេះ ។

បន្ទាប់ពីពួកគេបានផ្តល់អោយនូវគំនិតរបស់ពួកគេអ្នកអាចអោយពួកគេពិនិត្យមើលនូវគំនិតបន្ថែមទៀតដែលត្រូវបានផ្តល់ជូននៅទំព័រ ទី ២១ នៃសៀវភៅណែនាំរបស់សិស្សក្រោមចំនុច គ " តើផលប្រយោជន៍អ្វីនៃការប្រើអាកប្បកិរិយាខាងព្រះគម្ពីរ នៅពេលដែលគេកំពុងកែតម្រង់ និង តិទៀនខ្ញុំ? "

សូមចង្អុលបង្ហាញថា ការប្រព្រឹត្តរបស់យើងបង្ហាញនូវអាកប្បកិរិយាពិតរបស់យើង ។ អ្នកមិនអាចឆ្លើយតបជាមួយនឹងការប្រព្រឹត្តដ៏សមរម្យ នៅពេលដែលគេកំពុងតែកែតម្រង់អ្នកនោះទេ លុះត្រាណាតែអ្នកមានអាកប្បកិរិយាខាងព្រះគម្ពីរ ។

## ១៤. តើបញ្ហាអ្វីដែលទាក់ទងទៅនឹងអាកប្បកិរិយានេះ? (៥-១៥ នាទី )

សិស្សរបស់អ្នកនឹងមានការងាយស្រួលច្រើនក្នុងការធ្វើបញ្ជីនៃបញ្ហាទី ១ ដែលនឹងជួបប្រទះពេលដែលពួកគេព្យាយាមប្រើអាកប្បកិរិយាខាងព្រះគម្ពីរថ្មីនេះ នៅពេលដែលពួកគេត្រូវបានគេកែតម្រង់ ឬក៏ តិទៀននោះ ។

សូមអោយពួកគេធ្វើបញ្ជីនៃបញ្ហាដែលទាក់ទងទៅនឹងអាកប្បកិរិយានេះ ។ សរសេរគំនិតរបស់ពួកគេនៅលើក្តាខៀន ឬក៏ នៅលើម៉ាស៊ីនបញ្ចាំងស្លាយ ឬក៏ ក្រដាសមួយដ៏ធំ ។ អនុញ្ញាតអោយពួកគេបង្ហាញបញ្ជីនៃការដោះសារដែលពួកគេមានផងដែរ ថាតើហេតុបានជាអកប្បកិរិយាខាងព្រះគម្ពីរនេះមិនដំណើរការ ។

បន្ទាប់ពីពួកគេបានបង្ហាញនូវគំនិតរបស់ពួកគេ សូមពិនិត្យមើលនូវបញ្ជីដែលបានផ្តល់ជូននៅទំព័រ ទី ២១-២៣ ក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីមើលប្រសិនបើអ្នកចង់បន្ថែមបញ្ហាបន្ថែមទៀតចំពោះបញ្ជីរបស់ពួកគេ ។

កុំមានអារម្មណ៍ថាគេគៀបសង្កត់ក្នុងការធ្វើអោយត្រឹមត្រូវអាកប្បកិរិយាខាងព្រះគម្ពីរនេះប្រឆាំងទៅនឹងរាល់បញ្ហាដែលពួកគេបង្ហាញ ។

កុំអនុញ្ញាតអោយផ្នែកនៃពេលវេលារបស់ថ្នាក់នេះជាប់នៅក្នុងការមានការបកស្រាយអវិជ្ជមានច្រើនពេក ។ សូមចង្អុលបង្ហាញថា បញ្ហាទាំងអស់នេះមិនមានន័យថា វាមិនអាចបង្កើតអោយមានអាកប្បកិរិយាខាងព្រះគម្ពីរនោះទេ ។ វាគ្រាន់តែចង្អុលបង្ហាញថា វាមានការលំបាកច្រើនសំរាប់មនុស្សដែលពិតជាចង់បង្កើតអាកប្បកិរិយា ខាងព្រះគម្ពីរដើម្បីប្រើនៅពេលដែលគេកែតម្រង់ខ្លួន ។

## ១៥. តើខ្ញុំចាប់ផ្តើមបង្កើតអាកប្បកិរិយាខាងព្រះគម្ពីរដោយរបៀបណា? (១០-២០ នាទី )

សូមបង្ហាញដល់សិស្សនូវជំហ៊ានផ្សេងៗ គ្នាជាច្រើនដែលពួកគេអាចប្រើ ក្នុងការបង្កើតអាកប្បកិរិយាខាងព្រះគម្ពីរនេះនៅក្នុងជីវិតរបស់ពួកគេ ។ សូមប្រើសម្ភារៈនៅលើទំព័រ ទី ២៦ នៃសៀវភៅណែនាំរបស់សិស្សត្រង់ចំនុចនេះ ។ សូមយោងផងដែរទៅទំព័រ ទី ៧-១២ នៅក្នុងសៀវភៅណែនាំរបស់សិស្សដែលផ្តល់នូវជំហ៊ានទូទៅខ្លះៗនៅលើការបង្កើតអាកប្បកិរិយាថ្មី ។

## ១៦. ពិភាក្សាតារាងនៅទំព័រ ទី ២៤-២៥ នៃសៀវភៅណែនាំរបស់សិស្ស (៥-១៥ នាទី )

នៅត្រង់ចំនុចនេះអ្នកអាចពិភាក្សាតារាងធំនៅលើអាកប្បកិរិយានេះក្នុង ទំព័រ ទី ២៤ និង ២៥ នៃសៀវភៅណែនាំរបស់សិស្ស ។ សូមផ្តោតទៅលើការពិភាក្សានៅលើជួរ ទី ៤ និង ទី ៥ ដែលមានចំណងជើងថា " តើខ្ញុំគួរតែនិយាយអ្វី? " និង " តើខ្ញុំគួរតែធ្វើអ្វី? " ។

សូមពន្យល់ថា ជួរ " គុណភាពវិជ្ជមានខាងក្នុង " គឺជាផ្នែកនៃការអភិវឌ្ឍន៍ចរិកលក្ខណៈដ៏វែងដែលជួយពង្រឹងអាកប្បកិរិយាថ្មីដែលពួកគេនឹងបង្កើតឡើង ។

## ១៧. កំណត់សំគាល់នៅលើជំរើស ទី ១ សំរាប់មេរៀន ទី ៤

អ្នកប្រហែលជាមិនមានពេលវេលាក្នុងការបង្រៀន គ្រប់ទាំងគំនិតដែលត្រូវបានផ្តល់ជូនសំរាប់មេរៀននេះទាំងអស់ក្នុងមួយថ្នាក់នោះទេ ។ អ្នកអាចទុកគំនិតខ្លះៗដើម្បីធ្វើការពិភាក្សានៅក្នុងមេរៀន ទី ៤ ។ (សូមមើលសេចក្តីណែនាំសំរាប់ជំរើស ទី ១ នៅក្នុងផែនការមេរៀន របស់គ្រូសំរាប់មេរៀន ទី ៤ ទំព័រ ទី ២៨-៣១ ។)

ប្រសិនបើអ្នកសំរេចចិត្តប្រើជំរើស ទី ១សំរាប់មេរៀន ទី ៤ សូមធ្វើអោយប្រាកដថា ថ្ងៃនេះអ្នកបង្រៀនចំណុច ង " តើខ្ញុំចាប់ផ្តើមបង្កើតអាកប្បកិរិយានេះដោយរបៀបណា? " នៅទំព័រ ទី ២៦ នៃសៀវភៅណែនាំរបស់សិស្ស ។

## ១៨. ការអនុវត្តន៍ផ្ទាល់ខ្លួន

ផ្តោតការយកចិត្តទុកដាក់ការអនុវត្តន៍ផ្ទាល់ខ្លួនសំរាប់ថ្ងៃនេះនៅលើការចាប់ផ្តើមបង្កើតអាកប្បកិរិយាថ្មីនេះ ដើម្បីប្រើនៅពេលគេកែតម្រង់ ឬក៏ តិទៀន ។

ក. សូមពន្យល់ថា នៅថ្នាក់រៀនពេលក្រោយ ពួកគេនឹងមានសំនួរខ្លីៗនៅលើគំនិតទាំង ៥ ដែលបង្កើតឡើង អាកប្បកិរិយាខាងព្រះគម្ពីរដើម្បីប្រើនៅពេលគេកែតម្រង់ ឬក៏ តិទៀន ។

ខ. សូមលើកទឹកចិត្តពួកគេអោយចាប់ផ្តើម ទន្ទេញខគម្ពីរដែលស៊ីគ្នាជាមួយនឹងគំនិតនិមួយៗនៅក្នុងអាកប្បកិរិយានេះ ។ ពួកគេមិនធ្វើសំនួរនៅលើ ខគម្ពីរទាំងនេះនោះទេ ។

គ. សូមពន្យល់ថា គំរោង ទី ៤ " ការមើលឡើងវិញនូវការកែតម្រង់ និង ការតិទៀនពីអតីតកាល " គឺជាវិធីមួយទៀតសំរាប់ពួកគេចាប់ផ្តើមបង្កើតអាកប្បកិរិយានេះ ។

## ១៩. កិច្ចការត្រូវធ្វើ

ក. នៅពេលបញ្ចប់ថ្នាក់រៀនសូមផ្តល់សំនួរខ្លីៗ នៅលើ សុភាសិត ១០:១៧ ។

ខ. សូមពន្យល់ពីរបៀបគំរោង ទី ៤ស៊ីគ្នាជាមួយនឹងកិច្ចការពីគំរោង ទី ៣ " *បទពិសោធន៍អតីតកាលរបស់ខ្ញុំ ក្នុងការគេកែតម្រង់ និង តិទៀន ។* " គំរោង ទី ៤ ត្រូវតែបញ្ចប់អោយហើយនៅក្នុងមេរៀន ទិ ៤ ។

## ២០. ការវាយតំលៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក?

# មេរៀន ទី ៣
# ការកែតម្រង់អ្នកដទៃ

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំត្រូវតែទន្ទេញអោយចាំ និង ប្រើអាកប្បកិរិយាខាងព្រះគម្ពីរនៅពេលដែលខ្ញុំកំពុងតែកែតម្រង់អ្នកដទៃ ។

## ២. ខ គម្ពីរសំខាន់ៗ កាឡាទី ៦:១

បងប្អូនអើយ បើសិនជាមាននរណាម្នាក់ ត្រូវគេទាន់នៅពេលកំពុងតែធ្វើអំពើអាក្រក់ណាមួយ បងប្អូនដែលមានព្រះវិញ្ញាណ នៅក្នុងខ្លួនត្រូវកែតម្រង់អ្នកនោះដោយចិត្តស្លូតបូត ។ ក៏ប៉ុន្តែតោងប្រយ័ត្នខ្លួនក្រែងលោ អ្នកត្រូវធ្លាក់ក្នុងការល្បួងដូចគេដែរ ។

## ៣. យោងតាមឯកសាររបស់សិស្ស

នៅជំពូកទី ៤ ក្នុងសៀវភៅណែនាំរបស់សិស្ស (ទំព័រ ទី ២៧-៣៩) ស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោង ទី ៦-១០ នៅក្នុងការណែនាំការសិក្សាក៏ស៊ីគ្នាជាមួយនឹងមេរៀននេះផងដែរ ។

## ៤. ការចាប់ផ្តើមមេរៀន "ពន្យល់បង្ហាញពីឥដ្ឋ" (៣-៥ នាទី)

ណែនាំអោយស្គាល់មេរៀននេះជាមួយនឹងការពន្យល់បង្ហាញពីឥដ្ឋ ។ សូមមើលកំណត់សំគាល់របស់គ្រូ (ទំព័រ ទី ២៦-២៧) សំរាប់ការពន្យល់នៃការពន្យល់បង្ហាញនេះ ។

## ៥. បទពិសោធន៍ពីអតីតកាលនៃការកែតម្រង់អ្នកដទៃ (៣-៥ នាទី)

ដើម្បីអោយថ្នាក់រៀនកាន់តែល្អថែមទៀតនោះ អ្នកអាចអោយសិស្សច្រើននាក់ផ្តល់នូវឧទាហរណ៍មួយនៃឧទាហរណ៍របស់ពួកគេពីគំរោង ទី ៧ "*បទពិសោធន៍អតីតកាលរបស់ខ្ញុំ ក្នុងការកែតម្រង់ និង តិទៀនអ្នកដទៃ* ។"

ប្រសិនបើសិស្សមានការស្ទាក់ស្ទើរក្នុងការចែកចាយបទពិសោធន៍របស់ពួកគេ នោះអ្នកត្រូវតែផ្តល់ឧទាហរណ៍ផ្ទាល់របស់អ្នក ឬក៏ ស្ថានភាពដែលអ្នកបានអង្កេតថ្មីៗនេះ ។

## ៦. តើខ្ញុំគួរតែកែតម្រង់នរណា? (៥-១០ នាទី)

បង្រៀនដោយសង្ខេបពីបញ្ហាថាតើមនុស្សដែលអ្នកគួរតែកែតម្រង់គឺជានរណា ។ ចំលើយចំពោះសំនួរនេះអាចមានភាពខុសគ្នាដោយពឹងផ្អែកទៅលើថាតើនរណានៅក្នុងថ្នាក់របស់អ្នក ។ សូមចង្អុលបង្ហាញថា ការកែតម្រង់អ្នកដទៃគឺជាកាតព្វកិច្ចមិនមែនជាសេរីភាពនោះទេ ។

មានសំនួរពីរត្រូវតែគិតអោយបានប្រុងប្រយត្ន័

- តើមនុស្សដែលអ្នកគួរតែកែតម្រង់គឺជានរណា?
- តើនរណាផ្តល់អោយអ្នកមានកាតព្វកិច្ចកែតម្រង់មនុស្សទាំងនេះ?

បញ្ហាទាំងពីរខាងនេះសំខាន់ណាស់ក្នុងការបង្កើតអោយមានមូលដ្ឋានសំរាប់ថ្នាក់រៀននេះ ។ ប្រសិនបើពួកសន្មត់ថា ពួកគេអាចកែតម្រង់នរណាម្នាក់ក៏បានដែរ អោយតែធ្វើខុស នោះបញ្ហានឹងកើតមានឡើងជាមិនខាន ។ ធ្វើបញ្ជីឈ្មោះរបស់មនុស្សដែលពួកគេជឿថាពួកគេមានការទទួលខុសត្រូវក្នុងការកែតម្រង់ ។ សូមប្រើក្តាខៀន ឬក៏ម៉ាស៊ីនបញ្ចាំងស្លាយដើម្បីសរសេរចូលនូវចំលើយរបស់ពួកគេ ។

- សូមបង្ហាញមនុស្សនៅម្ខាង
- បន្ទាប់មកមើលបញ្ជីម្តងទៀត និង រកអោយឃើញថាតើនរណាបានផ្តល់អោយពួកគេនូវការទទួលខុសត្រូវក្នុងការកែតម្រង់បុគ្គលទាំងនោះ ។

ប្រភពនៃការទទួលខុសត្រូវដែលអាចរកបានខ្លះៗគឺឪពុកម្តាយ, ព្រះជាម្ចាស់, គ្រូគង្វាល, គ្រូបង្រៀន, មេក្រុមការងារ, ម្ចាស់ក្រុមហ៊ុន, ប៉ូលីស, ចៅក្រម, ច្បាប់របស់ប្រទេស, រដ្ឋ ឬក៏ ទីក្រុង, ច្បាប់ដែលបង្កើតឡើងដោយក្រុមមនុស្សមួយក្រុម ។ល។

ពេលដែលអ្នកបានធ្វើកិច្ចការនេះរួចហើយ សូមចោទសួរសំនួរ :

**តើមនុស្សនេះពិតជាមានសិទ្ធិអំណាចផ្តល់អោយអ្នកនូវការទទួលខុសត្រូវនោះឬទេ?**

ប្រសិនបើសិទ្ធិអំណាចនោះនឹងមានមុខងារនៅក្នុងឋានៈពិតប្រាកដរបស់គាត់ នោះអ្នកអាចកែតម្រង់មនុស្សដោយមានទំនុកចិត្តថា អ្នកកំពុងតែបំពេញនូវការទទួលខុសត្រូវរបស់អ្នក ។ សូមសង្កត់ធ្ងន់ទៅលើ តំរូវការចាប់បាច់ដើម្បីធ្វើកិច្ចការនេះជាមួយនឹងសេចក្តីស្រលាញ់ ។

ពតិមានបន្ថែមនៅលើប្រធានបទនេះត្រូវបានផ្តល់ជូននៅលើទំព័រ ទី ២៧-២៨ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។

## ៧. ច្បាប់របស់មជ្ឈមណ្ឌលក្នុងការកែតម្រង់អ្នកដទៃ

ប្រសិនបើអ្នកនឹងបង្រៀននៅក្នុងមជ្ឈមណ្ឌល ឬក៏ ពន្ធកិច្ចដូចគ្នានេះ នោះដល់ពេលហើយឥឡូវនេះដើម្បីពិភាក្សានូវច្បាប់នៃកម្មវិធីរបស់អ្នក ។ ប្រសិនបើមជ្ឈមណ្ឌលរបស់អ្នកមិនមានច្បាប់ ឬក៏ គោលការណ៍នៅលើកិច្ចការនេះទេ នោះប្រហែលជាអ្នកនឹងចង់ពិភាក្សាកិច្ចការនេះជាមួយនឹងប្រធានរបស់អ្នក ធ្វើដូច្នេះអ្នកអាចនឹងផ្តល់នូវចំលើយយ៉ាងច្បាស់លាស់ដល់សិស្សរបស់អ្នក អំពីថាតើការទទួលខុសត្រូវរបស់ពួកគេគឺជាអ្វី ។

សូមធ្វើអោយច្បាស់លាស់ថាតើពួកគេមានការទទួលខុសត្រូវ ឬក៏ អត់ក្នុងការកែតម្រង់បុគ្គលិក ។ អ្នកអាចផ្តល់នូវគំនិតខ្លះៗចំពោះច្បាប់ទូទៅ ។ ឧទាហរណ៏ថា ពន្ធកិច្ចរបស់អ្នកមិនអនុញ្ញាតិអោយសិស្សកែតម្រង់បុគ្គលិកនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើបុគ្គលិកកំពុងបើកឡានដឹកសិស្ស និង មិនបានមើលឃើញនូវគ្រោះថ្នាក់ដែលអាចកើតឡើង នោះសិស្សគួរតែនិយាយអោយខ្លាំងៗ ប្រសើរជាងនៅស្ងៀម និង អោយគ្រោះថ្នាក់កើតឡើង ។

## ៨. ការមានអាគប្បកិរិយាខាងព្រះគម្ពីរនៅពេលកែតម្រង់អ្នកដទៃ (៥-១០ នាទី)

សូមបង្ហាញនូវសម្ភារៈថ្មីថាតើការមានអាគប្បកិរិយាខាងព្រះគម្ពីរនៅពេលកែតម្រង់អ្នកដទៃជាអ្វី-ចំនុច ខ នៅលើទំព័រទី ២៨-៣០ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។

នៅពេលដែលណែនាំផ្នែកនៃមេរៀននេះអោយស្គាល់ សូមពន្យល់ថា យើងនឹងពិភាក្សាវិធីសាស្ត្រផ្សេងៗគ្នានៃការកែតម្រង់អ្នកដទៃពេលក្រោយ ។ ឥឡូវនេះយើងចង់និយាយអំពីគំនិតដែលវាចូលមកឆ្លងកាត់ចិត្តគំនិតរបស់យើងនៅពេលដែលយើងរៀបចំកែតម្រង់នរណាម្នាក់ដែលបានធ្វើអ្វីមួយខុស ។

សូមពន្យល់នូវតំរូវការក្នុងការប្រើប្រាស់អាគប្បកិរិយាខាងព្រះគម្ពីរទោះបីជាវិធីសាស្ត្រណាក៏ដោយយើងប្រើ " ក្នុងការផ្តល់អោយនរណាម្នាក់នូវឥដ្ឋ " ។

## ៩. គន្លឹះសំខាន់ ៣ ចំពោះការជ្រើសរើសវិធីសាស្ត្រត្រឹមត្រូវក្នុងការកែតម្រង់អ្នកដទៃ (៥ នាទី)

សូមបង្ហាញអោយលឿននូវគន្លឹះសំខាន់ ៣ ចំពោះការជ្រើសរើសវិធីសាស្ត្រត្រឹមត្រូវក្នុងការកែតម្រង់អ្នកនរណាម្នាក់ ។ សូមមើលទំព័រ ទី ៣០-៣១នៃសៀវភៅណែនាំរបស់សិស្សសំរាប់ពតិមាននៅលើចំនុចនេះ ។ សូមព្យាយាមផ្តល់នូវការពន្យល់ខ្លះៗដើម្បីបញ្ជាក់អោយច្បាស់នូវគន្លឹះនិមួយៗទាំង ៣ នេះ ។

## ១០. វិធីសាស្ត្រខាងព្រះគម្ពីរក្នុងការកែតម្រង់អ្នកដទៃ (២៥-៤៥ នាទី)

សូមចំណាយពេលវេលាភាគច្រើននៅក្នុងពិភាក្សាពីវិធីសាស្ត្រខុសគ្នា១ខាងព្រះគម្ពីរក្នុងការកែតម្រង់អ្នកដទៃ ។ អត្ថបទខគម្ពីរសំខាន់១ផ្តល់នូវមូលដ្ឋានសំរាប់ផ្នែកនេះរបស់មេរៀន

កាឡាទី ៦:១

ម៉ាថាយ ១៨:១៥-១៧

២ ធីម៉ូថេ ៣:១៦

សូមអោយសិស្សអានអត្ថបទគម្ពីរដែលត្រូវបានបង្ហាញផ្សេង១គ្នាសំរាប់វិធីសាស្ត្រនិមួយ១ក្នុងការកែតម្រង់ ។ សូមពិភាក្សាយ៉ាងប្រុងប្រយត្ន័នូវចំនុចសំខាន់១ដែលត្រូវបានផ្តល់អោយនៅក្នុងអត្ថបទគម្ពីរនិមួយ១នៅលើរបៀបកែតម្រង់អ្នកដទៃ ។

អោយសិស្សប្រើចំលើយរបស់ពួកគេដើម្បីឆ្លើយសំនួរ ទី ១, ២ និង ទី ៣ នៅលើគំរោង ទី ៦ " ការមើលខាងព្រះគម្ពីរក្នុងការកែតម្រង់អ្នកដទៃ " ។ សូមភ្ជាប់វិធីសាស្ត្រទាំងនេះទៅនឹងគំនិតទាំង ៤ ដែលគួរតែបង្កើតឡើងនូវ អាកប្បកិរិយារបស់ពួកគេនៅពេលដែលពួកគេប្រើនូវវិធីសាស្ត្រទាំងនេះ ។

ព្យាយាមពន្យល់បង្ហាញពីជីវិតផ្ទាល់របស់អ្នក ឬក៏ ពន្យល់បង្ហាញនូវកិច្ចការស្រដៀងគ្នាដទៃទៀតពីរបៀបវិធីសាស្ត្រនិមួយ១ទាំងនេះត្រូវបានគេប្រើ និង លទ្ធផលរបស់វា ។ សូមមើលពតិមានដែលត្រូវបានផ្តល់ជូនផងដែរនៅក្នុងសៀវភៅណែនាំរបស់សិស្ស នៅ ទំព័រ ទី ៣១-៣៤

## ១១. ម៉ាថាយជំពូក ទី ១៨ជាគំរូក្នុងការកែតម្រង់អ្នកដទៃ

ផ្តល់នូវការយកចិត្តទុកដាក់ពិសេសចំពោះគំរូនៃការកែតម្រង់ដែលត្រូវបានផ្តល់អោយ នៅក្នុង ម៉ាថាយ ១៨:១៥-១៧ ។ សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការប្រើប្រាស់នូវការណែនាំទាំងនេះ ឥឡូវនេះនៅពេលដែលពួកគេកែតម្រង់នរណាម្នាក់ ។ ប្រសិនបើមនុស្សនឹងធ្វើតាម គំរូដែលផ្តល់អោយនៅក្នុងម៉ាថាយ ១៨ នោះការប្រកែកគ្នា និង ការបែកបាក់ទំនាក់ទំនងនឹងត្រូវបានការពារមិនអោយកើតបញ្ហាទាំងនេះច្រើន ។

អ្នកអាចអោយសិស្សមើលនូវឧទាហរណ៍របស់ពួកគេនៅលើគំរោង ទី ៧ " បទពិសោធន៍អតីតកាលរបស់ខ្ញុំក្នុងការកែតម្រង់ និង តិទៀនអ្នកដទៃ " ដើម្បីអោយមើលឃើញថា ប្រសិនបើពួកគេបានកែតម្រង់មនុស្សក្នុងលក្ខណៈផ្ទាល់ខ្លួន ឬក៏ មានអ្នកដទៃមានវត្តមាននៅពេលនោះដែរ ។

## ១២. គំរូនៃការកែតម្រង់ពី ២ ធីម៉ូថេ៣:១៦ (នាទី ☆)

សូមពន្យល់ពីដំបូងថា ២ ធីម៉ូថេ ៣:១៦ គឺមិនពិភាក្សាចំៗពីរបៀបមនុស្សគួរតែកែតម្រង់គ្នាទៅវិញទៅមក ។

អត្ថន័យនៃអត្ថបទព្រះគម្ពីរនឹងពិភាក្សាពីរបៀបព្រះគម្ពីរអាចត្រូវបានប្រើនៅក្នុងជីវិតរបស់គ្រីស្តបរិស័ទ ។ ទោះជាយ៉ាងណាក៏ដោយ ចំនុចសំខាន់ៗទាំង ៤ នៃអត្ថបទគម្ពីរនេះបានផ្តល់អោយយើងនូវគោលការណ៍ខាងព្រះគម្ពីរល្អៗ ដើម្បីប្រើពេលកែតម្រង់អ្នកដទៃ ។

សូមព្យាយាមផ្តល់នូវឧទាហរណ៍ជាក់លាក់ពីរបៀបអ្នក ឬក៏ អ្នកដទៃបានប្រើនូវវិធីសាស្ត្រទាំងនេះ ។ អ្នកអាចអោយសិស្សធ្វើការវាយតំលៃវិធីសាស្ត្រមួយដែលព្រះយេស៊ូបានប្រើនៅក្នុងស្ថានភាពនេះ ។

ក. អ្នកគ្រប់គ្រងវ័យក្មេងជាអ្នកមាន ម៉ាកុស ១០:១៧-២២

ខ. បណ្ឌិតខាងវិន័យ លូកា ១០:២៥-៣៨

គ. ស្ត្រីប្រព្រឹត្តសហាយស្មន់ យ៉ូហាន ៨:១-១១

ឃ. ពេត្រុស ម៉ាថាយ ១៦:២១-២៨

## ១៣. ចំនុចសំខាន់ៗខ្លះសំរាប់កែតម្រង់អ្នកដទៃ (៥-១០នាទី)

សូមបង្រៀននូវសម្ភារៈដែលត្រូវបានផ្តល់អោយនៅទំព័រ ទី ៣៤-៣៥នៃសៀវភៅណែនាំរបស់សិស្សក្រោមចំនុច " តើចំនុចសំខាន់ៗអ្វីខ្លះសំរាប់កែតម្រង់អ្នកដទៃ? " សូមសង្កត់ទៅលើសេចក្តីពិតសាមញ្ញ ៣ នៅក្នុង យ៉ាកុប ១:១៩ ។

ក. ប្រុងប្រៀបស្តាប់

ខ. កុំប្រញាប់និយាយ

គ. កុំប្រញាប់ខឹង

☆ ពេលវេលា២៥-៤៥ នាទីត្រូវបានបង្ហាញ
សំរាប់សកម្មភាពលេខ ១០ រួមបញ្ចូលទាំងពេល
វេលាដែលអ្នកនឹងចំណាយសំរាប់សកម្មភាព
លេខ ១០, ១១ និង ១២ ។

## ១៤. ការកែតម្រង់អ្នកដទៃ និង ការអត់ទោសអោយអ្នកដទៃ(៥-១៥ នាទី)

អ្នកអាចអោយសិស្សពិភាក្សាចំលើយរបស់ពួកគេចំពោះសំនួរ ទី ៤ និង ទី ៥ នៅលើគំរោង ទី ៦ " ការមើលខាងព្រះគម្ពីរក្នុងការកែតម្រង់អ្នកដទៃ " ។

(៤) តើព្រះយេស៊ូមានព្រះបន្ទូលដូចម្តេចអំពីការអត់ទោសឱ្យអស់អ្នកដែលបានធ្វើបាបនឹងអ្នក ។ ម៉ាថាយ ១៨:១៥-២២

(៥) តើយោបល់អ្នកយ៉ាងដូចម្តេច? តើអ្នកគួរអត់ទោសឱ្យគ្រីស្ទបរិស័ទ ទោះបីគាត់បដិសេធន៍មិនស្តាប់អ្នក នៅពេលដែលអ្នកព្យាយាមកែតម្រង់គាត់ក៏ដោយឬ? សូមពន្យល់ចំលើយរបស់អ្នក

សំនួរទាំង ពីរលើកឡើងនូវចំនុចសំខាន់អំពីដំណើរការនៃការកែតម្រង់អ្នកដទៃ ។ ទោះបីជាសិស្សធ្វើតាមយ៉ាងប្រុងប្រយត្ន័នូវការណែនាំខាងព្រះគម្ពីរនៅពេលកំពុងតែកែតម្រង់អ្នកណាម្នាក់ក៏ដោយ ក៏មនុស្សនោះនៅតែឆ្លើយតបនៅក្នុងផ្លូវមួយដែលមិនចង់ស្តាប់នោះដែរ ។

សិស្សរបស់អ្នកមិនត្រូវសន្មត់ថា ការប្រើអាកប្បកិរិយា និង វិធីសាស្រ្តខាងព្រះគម្ពីរនឹងធានាថាមាន ការពិភាក្សាប្រកបទៅដោយសុខសាន្ត និង ជោគជ័យនោះដែរ ។ ពួកគេត្រូវតែរៀបចំខ្លួនជាស្រេចសំរាប់កំហឹង ឬក៏ពាក្យមិនពិសោះស្តាប់ដែលគេនឹងនិយាយនៅក្នុងទឹកមុខរបស់ពួកគេនៅពេលដែលពួកគេព្យាយាមធ្វើអ្វីដែលត្រឹមត្រូវ ។

អត្ថន័យនៃការអត់ទោសដ៏ពិតប្រាកដឆាប់ៗនឹងក្លាយទៅជាភស្តុតាងនៅពេលដែលត្រូវប្រឈមមុខជាមួយនឹងស្ថានភាពបែបនេះ ។ សូមចង្អុលបង្ហាញថា យើងត្រូវប្រើអាកប្បកិរិយាខាងព្រះគម្ពីរនៅពេលដែលកែតម្រង់ អ្នកដទៃ និង ឆ្លើយតបជាមួយនឹងការអត់ទោស ទោះបីជាពួកគេមានប្រតិកម្មយ៉ាងម៉េចក៏ដោយចំពោះការកែតម្រង់របស់យើង ។

## ១៥. ការកំណត់ខាងព្រះគម្ពីរនៅលើការកែតម្រង់អ្នកដទៃ (១០-២០ នាទី)

បន្ទាប់មកបង្រៀនចំនុច ង " តើការដាក់កំហិតខាងព្រះគម្ពីរអ្វីខ្លះក្នុងការកែតម្រង់អ្នកដទៃ? " សូមមើលទំព័រ ទី ៣៦-៣៨ សំរាប់ពត៏មាននៅលើចំនុចទាំងនេះ ។ អ្នកអាចអោយសិស្សពិភាក្សាចំលើយរបស់ពួកគេចំពោះករណីសិក្សានៅលើគំរោង ទី ៦ (សំនួរទី ៦)

## ១៦. ការអនុវត្តន៍ផ្ទាល់ខ្លួន

សំរាប់ផ្នែកការអនុវត្តន៍ថ្ងៃនេះ អោយសិស្សរបស់អ្នកធ្វើកិច្ចការ ៣ យ៉ាង ។

ក. លើកទឹកចិត្តពួកគេអោយចងចាំគំនិតទាំង ៤ ដែលត្រូវបានរួមបញ្ចូលនៅក្នុងអាកប្បកិរិយាខាងព្រះគម្ពីរ ដើម្បីប្រើនៅពេលកែតម្រង់អ្នកដទៃ ។ សូមមើលទំព័រ ទី ២៨-៣០នៃសៀវភៅណែនាំរបស់សិស្ស ។

ខ. សូមអោយពួកគេបង្កើតនូវជំនួយក្នុងការចងចាំ

សូមអោយសិស្សនូវក្រដាសសំរាប់សរសេរ ។ អោយពួកគេកត់ចូលនូវនៅលើក្រដាសនោះនូវ អាកប្បកិរិយាខាងព្រះគម្ពីរដើម្បីប្រើនៅពេលកែតម្រង់អ្នកដទៃ ។ សូមផ្តល់អោយពួកគេនូវប៊ិចសំរាប់ សរសេរ ឬក៏ ខ្មៅដៃពណ៌ដើម្បីលំអក្រដាសរបស់ពួកគេទៅតាមវិធីដែលពួកគេចង់ធ្វើ ។

សូមអោយពួកគេសរសេរចូលផងដែរនូវគំនិតសំខាន់ៗដទៃទៀតនៅលើក្រដាសដែលពួកគេត្រូវតែ ចងចាំនៅពេលកែតម្រង់នរណាម្នាក់ ។ ឧទាហរណ៍ ពួកគេអាចសរសេរនូវ ខគម្ពីរដែលត្រូវបានពិភាក្សា ថ្ងៃនេះ ។ នៅពេលដែលពួកគេសរសេររួចរាល់ហើយ លើកទឹកចិត្តអោយពួកគេបិទនៅក្នុងបន្ទប់របស់ពួក គេ ។

## ១៧. កិច្ចការត្រូវធ្វើ

ក. ដាក់ពិន្ទុគំរោង ទី ២ និង ទី ៦

ខ. សូមពន្យល់ពីរបៀបគំរោង ទី ៨ ស៊ីគ្នាជាមួយនឹងកិច្ចការដែលពួកគេបានធ្វើនៅក្នុងគំរោង ទី ៧ ។ សូមចង្អុលបង្ហាញថា គោលដៅរបស់គំរោងនេះគឺដើម្បីជួយពួកគេអោយមើលឃើញពីរបៀបដែលពួកគេ អាចប្រើអាកប្បកិរិយាថ្មីខាងព្រះគម្ពីរនៅពេលកែតម្រង់អ្នកដទៃ ។

គ. នៅបញ្ចប់មេរៀន សូមផ្តល់នូវសំនួរខ្លីៗនៅលើ កាឡាទី ៦:១ ។

ឃ. ថ្ងៃនេះ ឬក៏ បន្ទាប់ពីមេរៀននេះ សូមផ្តល់សំនួរខ្លីនៅគំនិតដែលត្រូវបានរួមបញ្ចូលនៅក្នុងការប្រើ អាកប្បកិរិយាខាងព្រះគម្ពីរនៅពេលត្រូវបានគេកែតម្រង់ ។ ពួកគេចាំបាច់ត្រូវតែសរសេរពីការចងចាំនៅ ក្នុងលំដាប់លំដោយត្រឹមត្រូវនូវគំនិតទាំង ៥ ដែលត្រូវបានរួមបញ្ចូលនៅក្នុងអាកប្បកិរិយានេះ ។ (សូមមើល ទំព័រ ទី ១៤ នៃសៀវភៅណែនាំរបស់សិស)

ង. សូមពន្យល់ថា គំរោង ទី ៩ " ការប្រើអាកប្បកិរិយាថ្មីរបស់ខ្ញុំ នៅពេលដែលកែតម្រង់នរណាម្នាក់ " គឺអាច ជ្រើសរើសបាន ។ ពួកគេមិនចាំបាច់បំពេញវាមុននឹងបញ្ចប់មុខវិជ្ជានេះទេ ។

ច. ប្រសិនបើអ្នកជ្រើសរើស ជំរើស ទី ២ សំរាប់មេរៀនទី ៤ នោះអ្នកអាចអោយពួកគេបំពេញគំរោង ខ្លីដែលនឹងរៀបចំពួកគេសំរាប់ថ្នាក់នោះ ។

រៀបចំគំរោងធ្វើដូច្នេះពួកគេនាំយកមកក្នុងថ្នាក់នូវ ពីរ ឬក៏ បីឧទាហរណ៍ដែលបង្ហាញអាកប្បកិរិយារបស់ពួកគេចំពោះប្រធានបទជាក់លាក់ណាមួយដែលអ្នកនឹងមានផែនការដើម្បីពិភាក្សា ។ អ្នកអាចរៀបចំវាដូចគ្នាទៅនឹងទ្រង់ទ្រាយ គំរោង ទី ៣ ឬក៏ គំរោង ទី ៧ នៅក្នុងសៀវភៅណែនាំការសិក្សា សំរាប់មនុស្សមុខវិជ្ជានេះ ។

## ១៨. ការវាយតំលៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក?

# មេរៀនទី៣

## កំណត់ចំណាំរបស់គ្រូ

## ការពន្យល់បង្ហាញពីឥដ្ឋ

ការពន្យល់បង្ហាញនេះអាចត្រូវបានប្រើដើម្បីណែនាំឱ្យស្គាល់មេរៀន ទី ៣នៅលើការកែតម្រង់អ្នកដទៃ ។ សូមសូមចំនុច លេខ ៤ នៅលើទំព័រ ទី ១៨នៃសៀវភៅណែនាំនេះ ។

### អ្នកនឹងត្រូវការ

១. សូមយកឥដ្ឋបាយអពីរឬក៏ បីដុំ-ឥដ្ឋដែលគេប្រើដើម្បីសាងសង់ផ្ទះ ឬក៏ ចង្ក្រានកំដៅផ្ទះ ។

២. សូមបូ ឬក៏ របស់តែងលំអដែលគេប្រើដើម្បីខ្ចប់អំណោយ ។

៣. សូមយកកញ្ចប់តូចមួយដែលមានទំហំប៉ុន ឥដ្ឋ ឬក៏ ឡាំង និង រុំភ្ជាប់ ។

៤. សៀវភៅក្របរឹង

### ការរៀបចំ

១. យករបស់តែងលំអ និង បូមកដាក់ជុំវិញឥដ្ឋបាយអ ។

២. ប្រសិនបើអ្នកមិនមានប្រអប់តូចដែលមានទំហំប៉ុនឥដ្ឋ នោះសូមយកក្រដាសកាតតុងមកកាត់ និង រុំភ្ជាប់ ។ អ្នកនឹងត្រូវការក្រដាសកាតុងប្រហែលជា៥ ទៅ ៦ ។

៣. ប្រើហ្វឺតសរសេរ ដាក់ឈ្មោះនូវប្រអប់និមួយៗជាមួយនឹងចំណងជើងទាំងនេះ ។

- កុំជក់បារី
- កុំដាក់បណ្តាសា
- អត់ទោសអោយអ្នកដទៃ
- ស្តាប់បង្គាប់អ្នកដឹកនាំ
- ទប់ទលការល្បួង
- កុំនិយាយកុហក

៤. ដាក់ក្រដាសរុំសៀវភៅ និង សរសេរចំណងជើងនេះ

***របៀបសាងសង់ផ្ទះជាមួយឥដ្ឋ***

## ការបង្ហាញរូបភាព

តើគេធ្លាប់វាយអ្នកជាមួយនឹងឥដ្ឋឬទេ? " សូមរើសយកឥដ្ឋមួយ " ។ អ្នកខ្លះចូលចិត្តចោលឥដ្ឋដាក់គ្នាទៅវិញទៅមក ។ វិធីមួយដែលមនុស្សចោលឥដ្ឋគឺនៅពេលដែលពួកគេតិទៀនអ្នក ។ ទោះបីជានៅពេលនរណាម្នាក់ព្យាយាមកែតម្រង់អ្នកនៅក្នុងវិធីខាងព្រះគម្ពីរ វានៅតែមានការឈឺចាប់ ។ (នៅចំនុចនេះ អ្នកអាចចោលឥដ្ឋមួយដាក់ដល់សិស្សម្នាក់ ។)

នៅឱកាសដ៏កម្រមួយ មាននរណាម្នាក់នឹងកែតម្រង់អ្នកនៅក្នុងវិធីមួយសុភាពនោះ ។ ពួកគេអោយអ្នកនូវឥដ្ឋរុំជាអំណោយ ហើយនិយាយថា " សូមប្រើរបស់នេះ វានឹងជួយអ្នកអោយ ក្លាយកាន់តែដូចព្រះគ្រីស្ទ ។ " (សូមអោយសិស្សម្នាក់នូវឥដ្ឋជាមួយ នឹងរបស់កែលំអរ និង បូ ។)

" អំណោយខ្លះ " អ្នកនិយាយ " ឥដ្ឋមួយ! "

នៅក្នុងថ្នាក់ចុងក្រោយ យើងបាននិយាយថា ការដែលត្រូវគេកែតម្រង់អាចជួយអោយអ្នករីកចំរើន ។ " ប៉ុន្តែ " អ្នកនិយាយថា " នៅពេលមនុស្សចោលដុំថ្មដាក់ខ្ញុំ តើមនុស្សនោះជួយអោយខ្ញុំរីកចំរើនដោយរបៀបណា? សូមមើលជុំវិញខ្ញុំ ។ មានឥដ្ឋរាប់តោនដែលគេក្រាលនៅជុំវិញទីនេះ ។ រាល់ពេលវេលាខ្ញុំព្យាយាមធ្វើកិច្ចការនេះ ខ្ញុំជំពប់ដួលលើឥដ្ឋទាំងនេះ ។

អ្វីដែលកើតឡើងជារឿយៗនេះគឺមនុស្សធ្វើបានល្អក្នុងការមើលឃើញកំហុសរបស់យើង ។ នៅពេលដែលដល់ពេលចោលឥដ្ឋ គោលដៅរបស់ពួកគេនោះគឺល្អណាស់ ។ ប៉ុន្តែកំរមានមនុស្សដែលកែតម្រង់អ្នកចំណាយពេលពេលវេលាជួយអ្នកបង្កើតឡើងនូវកិច្ចការមានប្រយោជន៍ជាមួយនឹងឥដ្ឋដែលពួកគេចោលអោយអ្នកនោះទេ ។

នៅពេលអ្នកកែតម្រង់មនុស្សម្នាក់ដែលបានធ្វើអ្វីមួយខុស សូមអោយពួកគេនូវអំណោយពីរ -ឥដ្ឋមួយដុំ និង ជំនួយខ្លះៗពីរបៀបប្រើឥដ្ឋនោះអោយបានល្អត្រឹមត្រូវ ។ (អោយសិស្សឥដ្ឋមួយដុំ និងសៀវភៅដែលមានចំណងជើងថា *របៀបសាងសង់ផ្ទះជាមួយឥដ្ឋ ។* ) បន្ទាប់មកជួយមនុស្សអោយសាងសង់ " ឥដ្ឋ " របស់អ្នកនៅក្នុងជីវិតរស់នៅរបស់ពួកគេ ធ្វើដូច្នេះពួកគេអាចកាន់តែមានចរិកលក្ខណៈដូចព្រះគ្រីស្ទថែមទៀត ។

## ឃ្លាភ្ជាប់

គោលដៅដ៏សំខាន់របស់មេរៀនថ្ងៃនេះគឺដើម្បីស្វែងរកនូវអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលពីរបៀបកែតម្រង់អ្នកដទៃ ។

## មេរៀន ទី ៤

## ការណែនាំទូទៅ

### ១. អ្នកមានជំរើសពីរក្នុងការពិចារណារៀបចំផែនការមេរៀនសំរាប់ថ្ងៃនេះ

ជំរើស ទី ១ : សូមចំណាយពេលវេលានៅក្នុងថ្នាក់នៅលើអាកប្បកិរិយាដែលត្រូវបានបង្ហាញនៅក្នុង មេរៀន ទី ២ និង ទី ៣ មួយ ឬក៏ ទាំងពីរ ។

" អាកប្បកិរិយារបស់ខ្ញុំ នៅពេលគេកែតម្រង់ ឬក៏ តិទៀនខ្ញុំ "

" អាកប្បកិរិយារបស់ខ្ញុំ នៅពេលខ្ញុំកំពុងតែកែតម្រង់អ្នកដទៃ "

ជំរើស ទី ២ : សូមចំណាយពេលវេលានៅក្នុងថ្នាក់រៀនដែលទាក់ទងទៅនឹង អាកប្បកិរិយាមួយឬក៏ ច្រើនដទៃទៀតដែលអ្នកមានអារម្មណ៍ថាវាមានប្រយោជន៏ចំពោះថ្នាក់រៀនរបស់អ្នក ។

ជំរើសទាំងពីរនេះត្រូវបានគេពិភាក្សាយ៉ាងលំអិតនៅទំព័រខាងក្រោម ។

### ២. ប្រភពធនធានសំរាប់ធ្វើផែនការមេរៀនរបស់អ្នក

*ការបង្រៀនព្រះគម្ពីរប្រកបទៅដោយគំនិតច្នៃប្រឌិត* គឺជាសៀវភៅដែលសរសេរឡើងដោយលោក ឡារី រីឆាត នៅក្នុងជំពូក ទី ២១-២៤ មានគំនិតល្អខ្លះៗស្តីពីរបៀបធ្វើផែនការសំរាប់មេរៀន ។ គំនិតទាំងនេះនឹងមានប្រយោជន៏សំរាប់អ្នកក្នុងការរៀបចំសំរាប់ថ្នាក់រៀនរបស់អ្នកថ្ងៃនេះ ។

### ៣. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗសំរាប់មេរៀននេះ

សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗនៅថ្ងៃនេះនឹងផ្អែកទៅលើអ្វីដែលអ្នកជ្រើសរើសក្នុងការបង្រៀន ។ ប្រសិនបើអ្នកជ្រើសរើស ជំរើស ទី ១ " អាកប្បកិរិយារបស់ខ្ញុំ នៅពេលគេកែតម្រង់ឬក៏ តិទៀនខ្ញុំ " ឬក៏ " អាកប្បកិរិយារបស់ខ្ញុំ នៅពេលខ្ញុំកំពុងតែកែតម្រង់អ្នកដទៃ " អ្នកអាចប្រើសេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗពីមេរៀននៅក្នុងអតីតកាល ។

ប្រសិនបើអ្នកជ្រើសរើសជំរើស ទី ២ នោះអ្នកត្រូវតែសរសេរសេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗដោយផ្ទាល់ខ្លួនរបស់អ្នក ។ គោលបំណងនៃសេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗគឺដើម្បីសង្ខេបអោយមកត្រឹមតែមួយប្រយោគនូវ គោលបំណងដ៏សំខាន់របស់មេរៀនថ្ងៃនេះ ។

### ៤. ខ គម្ពីរសំខាន់សំរាប់មេរៀនថ្ងៃនេះ

ប្រសិនបើអ្នកជ្រើសរើសជំរើស ទី ១ ខគម្ពីរសំខាន់សំរាប់ថ្ងៃនេះអាចដូចគ្នាទៅនឹងខគម្ពីរសំរាប់មេរៀន ទី ២ ឬក៏ ទី ៣ ។ ប្រសិនបើអ្នកជ្រើសរើសជំរើស ទី ២ សូមព្យាយាមរកខ គម្ពីរដែលទាក់ទងយ៉ាងច្បាស់លាស់ទៅនឹងបញ្ហាដែលអ្នកចង់បង្រៀននៅក្នុងមេរៀននេះ ។

# មេរៀន ទី ៤ ជំរើស ទី ១
# អាកប្បកិរិយារបស់ខ្ញុំនៅពេលគេកែតម្រង់ខ្ញុំ
# អាកប្បកិរិយារបស់ខ្ញុំនៅពេលខ្ញុំកំពុងតែកែតម្រង់អ្នកដទៃ

## ១. សេចក្តីពិតនៃខ គម្ពីរសំខាន់ៗដូចគ្នានឹងមេរៀន ទី ២ ឬក៏ ទី ៣ ដែរ

____________________

____________________

____________________

____________________

## ២. ខ គម្ពីរសំខាន់ៗដូចគ្នានឹងមេរៀន ទី ២ ឬក៏ទី ៣

____________________

____________________

____________________

____________________

## ៣. គម្រោងយុទ្ធសាស្ត្រមេរៀនរបស់អ្នក

សូមធ្វើអោយប្រាកដថាអ្នកមានគំនិតច្បាស់លាស់ខ្លះនៅលើអ្វីដែលអ្នកចង់ពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះ ។ អ្នកអាចចំណាយពេលវេលាខ្លះៗពិភាក្សាសំនួរ ឬក៏ បញ្ហាពួកគេកំពុងតែមានក្នុងការព្យាយាមប្រើនូវអាកប្បកិរិយាទាំងពីរនេះ ។ សូមរៀបចំនូវផែនការផ្ទាល់ខ្លួនរបស់អ្នកអោយរួចជាស្រេចប្រសិនបើពួកគេមិនមានសំនួរទេនោះ ។

## ៤. ការប្រើករណីការសិក្សា

វាមានប្រយោជន៍ណាស់ក្នុងការពិភាក្សាករណីសិក្សានៃស្ថានភាព ដែលមនុស្សកំពុងតែប្រើអាកប្បកិរិយាទាំងនេះ ។ ឧទាហរណ៍របស់ពួកគេពីគំរោង ទី ៣ និង ទី ៧ នៅក្នុងសៀវភៅណែនាំការសិក្សាមានប្រយោជន៍ណាស់សំរាប់កិច្ចការនេះ ។ សូមអោយពួកគេរកអោយឃើញនូវអាកប្បកិរិយាអ្វីដែលមនុស្សទាំងពីរនាក់នេះមាន ។ វាប្រហាក់ប្រហែលទៅនឹងគំរូខាងព្រះគម្ពីរយ៉ាងដូចម្តេច? តើការឆ្លើយតបរបស់ពួកគេកាន់តែដូចខាងព្រះគម្ពីរយ៉ាងដូចម្តេច?

## ៥. ការប្រើល្ខោនខ្លីៗ និងការសំដែង

ឱ្យពួកគេលេងឆាកសំដែងទៅលើស្ថានភាពខ្លះៗដែលមនុស្សម្នាក់កំពុងតែកែតម្រង់អ្នកដទៃ ។ សូមអោយពួកគេនិយាយចេញមកនូវគំនិតរបស់ពួកគេ ។ *វិធីសាស្ត្រនៃការបង្រៀនប្រកបទៅដោយការច្នៃប្រឌិត* មានជំពូកមួយដ៏ល្អនិយាយពីរបៀបប្រើការសំដែងនៅក្នុងថ្នាក់ ។

ប្រភពធនធានល្អដទៃទៀតដែលពន្យល់ពីការប្រើល្ខោនខ្លីៗ និង ការសំដែងគឺមាននៅក្នុងសៀវភៅមានចំណងជើងថា *របៀបបង្កើតសកម្មភាពរៀនព្រះគម្ពីរ* ដោយលោក អែត ស្ទីវឹត និង លោក នីល ។ សៀវភៅនេះមានពីរភាគ ភាគទី ១ សំរាប់បង្រៀនមនុស្សពេញវ័យ និង មួយភាគទៀតសំរាប់បង្រៀនមនុស្សដែលរៀនពីថ្នាក់ ទី ៧ ដល់ ទី ១២ ។ សំរាប់ភាគទី ២ មានចំណងជើងដូចគ្នាទៅនឹងភាគ ទី ១ ដែរ ។

សូមសរសេរនៅផ្នែកដែលអ្នកចូលរួមសំដែង ធ្វើដូច្នេះពួកគេដឹង( និង អ្នកដឹង) ត្រូវធ្វើអ្វី ។

## ៦. ប្រើអត្ថបទព្រះគម្ពីរ

អ្នកអាចចំណាយពេលវេលាខ្លះ ក្នុងការពិភាក្សាអត្ថបទព្រះគម្ពីរ ដែលទាក់ទងទៅនឹងអាកប្បកិរិយាទាំងនេះ ។វានឹងប្រព្រឹត្តទៅល្អបំផុតប្រសិនបើអ្នករៀបចំមុនរៀននូវបញ្ជីយោងនៃអត្ថបទព្រះគម្ពីរដែលអ្នកចង់ពិភាក្សា ។ អ្នកអាចអោយសិស្សរកមើល ៥ គម្ពីរ និង កំណត់ពីរបៀបដែល៥គម្ពីរទាំងនេះទាក់ទងទៅនឹងអាកប្បកិរិយា ។

អ្នកអាចអោយថ្នាក់ទាំងមូលធ្វើកិច្ចការនេះទាំងអស់គ្នា ឬក៏ អោយពួកគេបង្កើតជាក្រុមតូច និងផ្តល់នូវបញ្ជីនៃអត្ថបទព្រះគម្ពីរ ។ សូមផ្តល់អោយក្រុមនិមួយៗនូវក្រដាសធំមួយសន្លឹក និង ប៊ិចសរសេរសំរាប់សរសេរចូលនូវអ្វីដែលពួកគេរកឃើញ ។ បន្ទាប់មកអោយក្រុមនិមួយៗធ្វើរបាយការណ៍ដល់ថ្នាក់ទាំងមូលនូវអ្វីដែលពួកគេបានរកឃើញនោះ ។

គំរោង ទី ១០ " ប្រាជ្ញា និង ការកែតម្រង់ខាងព្រះគម្ពីរ " នៅក្នុងសៀវភៅណែនាំការសិក្សាក៏អាចត្រូវបានប្រើដោយមានប្រសិទ្ធិភាពផងដែរនៅទីនេះ ។

## ៧. ការអនុវត្តន៍ផ្ទាល់ខ្លួន

ធ្វើការសន្និដ្ឋានថ្នាក់រៀនទាំងមូលជាមួយនឹងការអនុវត្តន៍ផ្ទាល់ខ្លួនដ៏សមរម្យ ។

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

## ៨. កិច្ចការគ្រូធ្វើ

ក. ដាក់ពិន្ទុគំរោង ទី ២ និង ទី ៤ ប្រសិនបើអ្នកមិនទាន់ធ្វើវារួចនោះ ។

ខ. ដាក់ពិន្ទុគំរោង ទី ៥ នៅថ្ងៃនេះ ឬក៏ នៅពេលសិក្សាវគ្គក្រោយ ។

គ. ដាក់ពិន្ទុគំរោង ទី ៧ និង ទី ៨ ។

ឃ. នៅពេលចុងបញ្ចប់ថ្នាក់រៀន សូមផ្តល់សំនួរទៅលើ " ការមានអាកប្បកិរិយាខាងព្រះគម្ពីរនៅពេលគេកំពុងតែកែតម្រង់ " ប្រសិនបើអ្នកមិនបានធ្វើកិច្ចការនេះនៅពេលចុងបញ្ចប់ថ្នាក់រៀនទេនោះ សូមមើល ទំព័រ ទី ១៤ នៃសៀវភៅណែនាំរបស់សិស្ស ។

## ៩. ការវាយតម្លៃរបស់គ្រូបង្រៀនសំរាប់វគ្គសិក្សានៅថ្ងៃនេះ

ក្រោយពីបញ្ចប់ថ្នាក់រៀនហើយ សូមសរសេរការវាយតម្លៃជាសង្ខេបសំរាប់វគ្គសិក្សានៅថ្ងៃនេះអោយបានលឿន ។ ខ្ញុំពិតជាចង់ឮពីអ្នកអំពីវគ្គសិក្សាថ្ងៃនេះ ។ ខ្ញុំនឹងសរសើរនូវកិច្ចការនេះមែនទែន ប្រសិនបើអ្នកអាចផ្ញើអោយខ្ញុំនូវក្រដាសថតចំលងនៃផែនការមេរៀនរបស់អ្នកសំរាប់ថ្ងៃនេះ និង ក្រដាសថតចំលងនៃការវាយតំលៃរបស់អ្នកនៅក្នុងថ្នាក់ ។ អ្នកអាចអោយ មួយ ឬក៏ ទាំងពីរនេះតែម្តងក៏បានវាមានប្រយោជន៍សំរាប់ខ្ញុំ ។ សូមអរគុណ ។ ដេវបាទី

## មេរៀន ទី ៤ ជំរើស ទី ២
## អាកប្បកិរិយានៃការជ្រើសរើសរបស់អ្នក

### ១. សេចក្តីពិតនៃខ គម្ពីរសំខាន់ៗ

___

___

___

___

### ២. ខ គម្ពីរសំខាន់ៗ

___

___

___

___

### ៣. ធ្វើផែនការយុទ្ធសាស្ត្រ

សូមចំណាយពេលវេលាកំឡុងពេលថ្នាក់រៀនអោយទាក់ទងទៅនឹងអាកប្បកិរិយា មួយ ឬក៏ ច្រើនដែលអ្នកគិតថាវាមានប្រយោជន៏ដល់ថ្នាក់រៀនរបស់អ្នក ។ នៅទំព័រ ទី ៧នៃសៀវភៅណែនាំរបស់សិស្សបង្ហាញនូវបញ្ជីខ្លះនៃអាកប្បកិរិយាដែលគ្រីស្តបរិស័ទថ្មីបានបង្ហាញនូវចំណាប់អារម្មណ៏នៅក្នុងការសិក្សា ។ គំរោង ទី ១ និង ទី ២មានសំនួរដែលអាចផ្តល់អោយអ្នកនូវគំនិតដ៏មានប្រយោជន៏នៅលើអ្វីដែលសិស្សរបស់អ្នកចង់សិក្សា ។

### ៤. រកអោយឃើញនូវចំណាប់អារម្មណ៏សិស្សរបស់អ្នក

ប្រសិនបើអ្នកចង់អោយសិស្សចូលរួមយ៉ាងសកម្មនៅក្នុងការសំរេចចិត្តថាតើអាកប្បកិរិយាអ្វីត្រូវសិក្សា សូមអោយពួកគេបញ្ចេញនូវយោបល់របស់ពួកគេមុននឹងចាប់ផ្តើមថ្នាក់រៀន ។ កិច្ចការនេះវាសំខាន់ណាស់ប្រសិនបើអ្នកចង់ផ្តល់កិច្ចការធ្វើដល់ពួកគេដែលទាក់ទងទៅនឹងអាកប្បកិរិយាដែលអ្នកនឹងរៀន ។

សូមមើលការណែនាំ ( ចំនុច ១៧ ច) នៅចុងបញ្ចប់នៃផែនការមេរៀន លេខ ៣សំរាប់កិច្ចការធ្វើនៅផ្ទះរបស់ពួកគេសំរាប់ថ្នាក់រៀនថ្ងៃនេះ ( ទំព័រ ទី ២៥) ។

## ៥. របៀបបង្កើតអាកប្បកិរិយាថ្មី

អ្នកអាចប្រើនៅពត៌មានខ្លះៗពីទំព័រ ទី ៧-១២នៅក្នុងសៀវភៅណែនាំរបស់សិស្សក្នុងគំរោងមេរៀនថ្ងៃនេះ ។ អោយសិស្សភ្ជាប់គំនិតនៅលើរបៀបបង្កើតអាកប្បកិរិយាថ្មីចំពោះប្រធានបទដែលអ្នកបានជ្រើសរើសសំរាប់ថ្នាក់រៀនថ្ងៃនេះ ។

## ៦. តើអ្វីទៅគឺជាការផ្តោតការយកចិត្តទុកដាក់របស់អ្នកសំរាប់មេរៀនថ្ងៃនេះ?

អ្នកត្រូវតែសំរេចចិត្តថាប្រធានបទខាងក្រោមអ្នកត្រូវរៀនរយៈពេលប៉ុន្មានចំពោះប្រធានបទនិមួយៗ ។

ក. បង្កើនការដឹងខ្លួននៃអាកប្បកិរិយាបច្ចុប្បន្នរបស់ពួកគេនៅក្នុងកន្លែងនេះ

ខ. តើពួកគេអាចចាប់ផ្តើមបង្កើតអាកប្បកិរិយាថ្មីក្នុងកន្លែងនេះនៃជីវិតរបស់ពួកគេនៅឯណា

## ៧. ប្រើអត្ថបទខគម្ពីរ

ត្រូវមានបញ្ជីនៃអត្ថបទខគម្ពីរជាច្រើនដែលទាក់ទងទៅនឹងអាកប្បកិរិយានេះ ។ អោយពួកគេរកអោយឃើញ និង ពន្យល់ពីរបៀបខគម្ពីរនិមួយៗទាក់ទងទៅនឹងអាកប្បកិរិយានេះ ។

## ៨. តើគំនិតអ្វីនឹងបង្កើតអាកប្បកិរិយាថ្មីនេះ?

បន្ទាប់មកអោយពួកគេបង្ហាញនូវគំនិតសំខាន់ខ្លះៗដែលនឹងត្រូវបានរួមបញ្ចូលនៅក្នុងអាកប្បកិរិយាថ្មីដែលយើងចង់បង្កើតឡើង ។ អ្នកអាចបង្កើតឡើងនូវអ្វីមួយដែលដូចគ្នាទៅនឹងអ្វីដែលអ្នកបានធ្វើជាមួយនឹងអាកប្បកិរិយាដែលត្រូវបានពិភាក្សានៅក្នុង មេរៀន ទី ២ និង ទី ៣ ។ ព្យាយាមអោយអោយមានអត្ថបទខ គម្ពីរស៊ីគ្នាជាមួយនឹងចំនុចនិមួយៗ ។

ពិភាក្សាការអនុវត្តន៏ដែលអាចអនុវត្តន៏ទៅបាននៃអាកប្បកិរិយាថ្មីនេះ ដោយប្រើឧទាហរណ៏របស់ពួកគេខ្លះៗពីកិច្ចការធ្វើនៅផ្ទះដែលអ្នកបានអោយពួកគេ ។

## ៩. ការអនុវត្តន៍ផ្ទាល់ខ្លួន

បង្កើតនូវការអនុវត្តន៍ផ្ទាល់ខ្លួនមួយដ៏សមរម្យសំរាប់មេរៀន ។ សូមផ្តោតទៅលើគំរូវការ មិនមែនគ្រាន់តែចង់ចាំគំរូនៃគំនិតថ្មីនេះទេ និង ត្រូវជំរុញពួកគេផងដែរអោយចាប់ផ្តើមអនុវត្តន៍វានៅក្នុងស្ថានភាពដែលពួកគេប្រឈមមុខនៅក្នុងសប្តាហ៍នេះ ។

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

## ១០. កិច្ចការត្រូវធ្វើ

ក. ដាក់ពិន្ទុគំរោង ពិសេសរបស់ពួកគេសំរាប់ថ្នាក់រៀនថ្ងៃនេះ ។ សូមដាក់ពិន្ទុនូវគំរោងដទៃទៀតពីសៀវភៅការណែនាំការសិក្សា ។

ខ. នៅពេលចុងបញ្ចប់ថ្នាក់រៀន សូមផ្តល់សំនួរទៅលើ " ការមានអាកប្បកិរិយាខាងព្រះគម្ពីរនៅពេលគេកំពុងតែកែតម្រង់ " ប្រសិនបើអ្នកមិនបានធ្វើកិច្ចការនេះនៅពេលចុងបញ្ចប់ថ្នាក់រៀនទេនោះ សូមមើល ទំព័រ ទី ១៤ នៃសៀវភៅណែនាំរបស់សិស្ស ។

## ១១. ការវាយតម្លៃរបស់គ្រូបង្រៀនសំរាប់វគ្គសិក្សានៅថ្ងៃនេះ

ក្រោយពីបញ្ចប់ថ្នាក់រៀនហើយ សូមសរសេរការវាយតម្លៃជាសង្ខេបសំរាប់វគ្គសិក្សានៅថ្ងៃនេះអោយបានលឿន ។ ខ្ញុំពិតជាចង់ឮពីអ្នកអំពីវគ្គសិក្សាថ្ងៃនេះ ។ ខ្ញុំនឹងសរសើរនូវកិច្ចការនេះមែនទែន ប្រសិនបើអ្នកអាចផ្ញើអោយខ្ញុំនូវក្រដាសថតចំលងនៃផែនការមេរៀនរបស់អ្នកសំរាប់ថ្ងៃនេះ និង ក្រដាសថតចំលងនៃការវាយតំលៃរបស់អ្នកនៅក្នុងថ្នាក់ ។ អ្នកអាចអោយ មួយ ឬក៏ ទាំងពីរនេះតែម្តងក៏បានវាមានប្រយោជន៍សំរាប់ខ្ញុំ ។ សូមអរគុណ ។ ដេវបាទី

# មេរៀន ទី ៥ :

# ការប្រឡង

**១. ណែនាំអោយស្គាល់នូវមុខវិជ្ជាដែលអ្នកនឹងបង្រៀនពេលក្រោយ**

**ក.** អោយសៀវភៅណែនាំរបស់សិស្ស និង ការណែនាំការសិក្សា និង ចាត់ចែងគំរោងដែលត្រូវបំពេញមុនរៀនរបស់មេរៀនបន្ទាប់ដែលអ្នកនឹងត្រូវបង្រៀន ។

**ខ.** អោយសិស្សមើលនៅទំព័រចុងក្រោយនៃសៀវភៅការណែនាំការសិក្សារបស់ពួគេ ។ ពួកគេនឹងឃើញបញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់ ។ ផ្តល់នៅកាលបរិច្ឆេទសំរាប់សំនួរខ្លីៗ, គំរោង និង ការប្រលងនិមួយៗ ។

**២. ផ្តល់ការប្រលងនៅលើមុខវិជ្ជានេះ**

**៣. ដាក់ពិន្ទុគំរោង ទី ៥, ៩ និង ១០ ។ គំរោង ទី ៩ និង ទី ១០ អាចជ្រើសរើសបាន ។**

**៤. សូមប្រគល់សំនួរខ្លីៗ និង គំរោងដែលអ្នកបានដាក់ពិន្ទួរួចហើយទាំងអស់ដល់សិស្ស ប្រសិនបើអ្នកមិនទាន់បានប្រគល់ជូននៅឡើយនោះ ។**